**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# សកម្មភាពអប់រំនៃ
# សាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក

កម្មសិក្សាពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **សាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **ខេង និមល**

**ភឹម នរ៉ា**

សាស្ត្រាចារ្យណែនាំ

លោក **ខួន ហេង**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី៣

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# អារម្ភកថា

ក្រោយពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ៤ ឆ្នាំកន្លងមកលើមុខវិជ្ជាវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានឈានមកដល់ដំណាក់កាលនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលទាមទាឲ្យនិស្សិតធ្វើការប្រឡង ឬក៏សរសេររបាយការណ៍ ឬសារណា។ ហេតុនេះហើយទើបក្រុមយើងខ្ញុំសម្រេចជ្រើសរើសការបញ្ចប់ ដោយការសរសេររបាយការណ៍ ហើយក្រោយពីបានពិភាក្សាជាមួយមិត្តរួមក្រុម និងសាស្ត្រាចារ្យណែនាំរួចមក យើងខ្ញុំទាំងពីរក៏សម្រេចយកប្រធានបទដែលនិយាយអំពី «សកម្មភាពអប់រំរបស់សាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក»។

មូលហេតុដែលធ្វើឲ្យក្រុមយើងខ្ញុំធ្វើការសិក្សាលើប្រធានបទនេះ គឺដោយសារតែការអប់រំជាកត្តា មួយដែលឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ទៅលើធនធានមនុស្ស ដែលជាកត្តាជម្រុញការអភិវឌ្ឍន៍ របស់ប្រទេសក្នុងចំណោមកត្តាដទៃទៀត ដូចជាកត្តាធនធានធម្មជាតិ និងកត្តាបច្ចេកវិទ្យាផងដែរ។ បើទោះបីជាយ៉ាងណាក៏ដោយចុះ សាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក គឺជាស្ថាប័នឯកជនមួយដែល បណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព និងបរិមាណ។

យើងខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំដែលជាសមិទ្ធិផលដ៏ស្ដួចស្ដើងនេះ និងអាចឆ្លុះបញ្ចាំងពីកម្មវិធិសិក្សា វិន័យ គុណភាព និងសេវាកម្មដែលទាក់ទងជាមួយនឹងការសិក្សារបស់ សិស្សនៅក្នុងសាលារៀនសុវណ្ណភូមិ សាខាបឹងត្របែក។ យើងខ្ញុំក៏សូមអភ័យទោសចំពោះកំហុសឆ្គង ដែលកើតមានឡើង ដោយប្រការណាមួយ និងស្វាគមន៍ចំពោះមតិរិះគន់ពីសំណាក់សាស្ត្រាចារ្យ លោក លោកស្រី និងមិត្តនិស្សិត ដើម្បីកែសម្ពន្ធវឯកសារស្រាវជ្រាវនេះអោយកាន់តែល្អប្រសើរ។

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ខេង និមល និង ភឹម នរ៉ា ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី៤ ជំនាន់ទី ៣ ក្រុម D4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច សូមសម្តែងនូវអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅព្រមទាំងការគោរពដឹងគុណដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ៖

១. អ្នកម្ដាយ ខេង សុផល

២. លោកឪពុក ភឹម សំអាត និងអ្នកម្ដាយ ជិន ធឿង

ដែលលោកបានផ្ដល់កំណើតដល់រូបកូន ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ គាំទ្រព្រមទាំងលើកទឹកចិត្តទាំងផ្នែកស្មារតី និងថវិការរហូតដល់កូនៗ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

៣. ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ និងបុគ្គលិកនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានយកចិត្តទុកដាក់បង្រៀន និងបំពេញការងារផ្សេងៗ ដែលជម្រុញដល់ការសិក្សាដល់ក្រុមយើងខ្ញុំ។

៤. លោកសាស្ត្រាចារ្យ ងួន ហេង ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរ និងរៀបចំនូវរបាយការណ៍កម្មសិក្សានេះ។

៥. លោក នាយក ហ៊ុន លឹមតួ និង អ្នកសម្របសម្រួលថ្នាក់ចំណេះទូទៅខ្មែរលោក ម៉ុម ហាញ ព្រមទាំងលោកគ្រូ អ្នកគ្រូ និង បុគ្គលិកគ្រប់ផ្នែកទាំងអស់ដែលជួយផ្ដល់នូវឯកសារផ្សេងៗ និងសម្រួលដល់ការងារមួយនេះ។

ជាចុងបញ្ចប់នេះផងដែរ យើងខ្ញុំសូមជូនពរដល់លោកអ្នកដែលមានគុណទាំងអស់ឲ្យជួបប្រទះ តែសុខសុភមង្គល និងទទួលបានពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

## សេចក្តីផ្តើម

១. លំនាំបញ្ហា......១
២. ការកំណត់បញ្ហា......២
៣. កម្មវត្ថុនៃការស្រាវជ្រាវ......២
៤. សារៈសំខាន់នៃការស្រាវជ្រាវ......២
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ......៣
៦. វិធីសាស្ត្រស្រាវជ្រាវ......៣

## ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ

១.១ និយមន័យអប់រំ......៥
១.២ គោលបំណងនៃការអប់រំនៅប្រទេសកម្ពុជា......៥
១.៣ ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា......៦
១.៣.១ ដំណើរការវិវត្តន៍នៃប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា......៦
១.៣.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និង កីឡា......១០
១.៣.៣ យុទ្ធសាស្ត្រ និង ផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ......១១
១.៣.៤ កម្មវិធីសិក្សាជាតិ......១៣
១.៤ លក្ខណ្ឌបើកសាលារៀនចំណេះទូទៅឯកជន......១៣
១.៥ ប្រព័ន្ធអប់រំនៅបណ្តាលប្រទេសកំពុងអភិវឌ្ឍមួយចំនួន......១៥
១.៥.១ ប្រព័ន្ធអប់រំនៅក្នុងប្រទេសថៃ......១៦
១.៥.២ ប្រព័ន្ធអប់រំនៅក្នុងប្រទេសឡាវ......១៦
១.៥.៣ ប្រព័ន្ធអប់រំនៅក្នុងប្រទេសមីយ៉ាន់ម៉ា......១៧
១.៦ សេចក្តីសន្និដ្ឋានក្នុងជំពូកទ្រឹស្តី......១៧

## ជំពូកទី២ ស្ថានភាពទូទៅនៅសាលារៀន សុវណ្ណភូមិបឹងត្របែក

២.១ ប្រវត្តិ នៃសាលារៀន សុវណ្ណភូមិបឹងត្របែក......១៨
២.២ ទីតាំងនៃសាលារៀន សុវណ្ណភូមិបឹងត្របែក......១៩
២.៣ ផ្លាកសញ្ញា......១៩
២.៤ ចក្ខុវិស័យ និង បេសសកម្ម......២០

២.៤.១ ចក្ខុវិស័យ ..................................................................................................................២០
២.៤.២ បេសសកម្ម ................................................................................................................២០
២.៥ រចនាសម្ព័ន្ធគ្រប់គ្រងនៃសាលារៀន សុវណ្ណភូមិបឹងត្របែក..............................................២០
២.៦ សកម្មភាពអប់រំនៃសាលារៀន សុវណ្ណភូមិបឹងត្របែក......................................................២១
២.៦.១ លក្ខខណ្ឌចូលរៀន.........................................................................................................២១
២.៦.២ កម្មវិធីសិក្សា ................................................................................................................ ២២

**ជំពូកទី៣៖ សកម្មភាពអប់រំថ្នាក់បឋមសិក្សាជាភាសាជាតិរបស់សាលារៀនសុវណ្ណភូមិ សាខាបឹងត្របែកក្នុងឆ្នាំ២០១៩**

៣.១ ផ្នែកអប់រំ.......................................................................................................................២៦
៣.១.១ លក្ខខណ្ឌចូលរៀន ........................................................................................................២៦
៣.១.១.១ កម្រិតអាយុសិស្ស...................................................................................២៦
៣.១.១.២ ការធ្វើតេស្តកំណត់កម្រិតសិក្សា .............................................................២៦
៣.១.២ កម្មវិធីសិក្សា ................................................................................................................ ២៧
៣.១.៣ សម្ភារៈឧបទេសសិក្សា ..................................................................................................២៩
៣.១.៤ បណ្ណាល័យ.................................................................................................................. ៣០
៣.១.៥ វិន័យ ........................................................................................................................... ៣០
៣.១.៦ អាហារូបករណ៍(រង្វាន់សិស្សពូកែ) ................................................................................ ៣៥
៣.១.៧ ការប្រកួតប្រជែងផ្សេងៗ ............................................................................................... ៣៦
៣.១.៨ សេវាកម្មបន្ថែម...............................................................................................................៣៧
៣.២ ផ្នែករដ្ឋបាល ................................................................................................................... ៣៩
៣.២.១ នីតិវិធីក្នុងការជ្រើសរើសគ្រូបង្រៀនចំណោះទូទៅខ្មែរ............................................... ៣៩
៣.២.២ ប្រព័ន្ធវាយតម្លៃលើការបង្រៀនរបស់គ្រូ ....................................................................... ៤០
៣.២.៣ ការចុះអធិការកិច្ចរបស់មន្ទីរអប់រំ យុវជន និង កីឡា.........................................................៤១
៣.៣ សមិទ្ធផលសម្រេចបានកន្លងមករបស់សាលារៀន សុវណ្ណភូមិបឹងត្របែក ........................ ៤១
៣.៤ ទស្សនៈវិស័យពេលអនាគត.................................................................................................៤២

**ជំពូកទី៤៖ ការវិភាគទៅលើទិន្នន័យសិស្សពីខែមករា ដល់ខែមីនាក្នុងឆ្នាំ២០១៩**

៤.១ ទិន្នន័យនិងការវិភាគសិស្សបឋមសិក្សាជាភាសាជាតិពីខែមករា ដល់ខែមីនា .................... ៤៣

៤.១.១ តារាងទិន្នន័យ និងការវិភាគចំនួនសិស្សថ្នាក់បឋមសិក្សា.................................... ៤៣
៤.១.២ ការវិភាគចំនួនសិស្សតាមក្រាហ្វិច.................................................................. ៤៤
៤.២ ការវិភាគSWOT.......................................................................................... ៤៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១.សេចក្តីសន្និដ្ឋាន.................................................................................................. ៤៧
២.ការផ្តល់អនុសាសន៍ ............................................................................................. ៤៨

**ឧបសម្ព័ន្ធ**

**ឯកសារយោង**

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ដែលទាមទារឲ្យរដ្ឋាភិបាលរិះរកគ្រប់យុទ្ធសាស្ត្រទាំង ឡាយក្នុងការអភិវឌ្ឍន៍ទៅលើគ្រប់វិស័យ ដើម្បីបង្កើតបាននូវការរីកចម្រើនទាំងសង្គម និងសេដ្ឋកិច្ច។ នៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិមួយ គឺត្រូវមានការចូលរួមពីវិស័យជាច្រើន និងរយៈពេលយូរផងដែរ។ វិស័យទាំងនេះមានដូចជា វិស័យកសិកម្ម វិស័យសុខាភិបាល វិស័យដឹកជញ្ជូន វិស័យអប់រំ វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម។ល។ នៅក្នុងនោះយើងសង្កេតឃើញថា វិស័យអប់រំ គឺជាវិស័យស្នូលមួយដែលផ្តល់នូវធនធានមនុស្សទៅដល់វិស័យផ្សេងៗ ទៀតក្នុងការអភិវឌ្ឍន៍ ប៉ុន្តែវាទាមទានូវភាពអត់ធ្មត់ក្នុងការបណ្តុះបណ្តាល ដើម្បីទទួលបាននូវសមិទ្ធផលមកវិញ។

## ១. លំនាំបញ្ហា

ការអប់រំនៅប្រទេសកម្ពុជា បានរីកលូតលាស់តាំងពីសម័យអាណានិគមនិយមបារាំងមកម្លេះ ប៉ុន្តែត្រូវបានបំផ្លាញទៅវិញដោយរបបខ្មែរក្រហមទាំងហេដ្ឋារចនាសម្ព័ន្ធអប់រំ ធនធានមនុស្ស និងជាពិសេសបញ្ញវន្ត។ ក្រោយមក នៅពេលដែលរបបនេះត្រូវបានដួលរលំ វិស័យអប់រំត្រូវបានយកចិត្តទុកដាក់ឡើងវិញដោយរដ្ឋាភិបាល ហើយរហូតដល់មានការជ្រោមជ្រែងពីសំណាក់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិមួយចំនួនទៀតផង ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក។

ក្នុងចំណោមកម្រិតសិក្សាទាំងអស់យើងសង្កេតឃើញថា ការអប់រំថ្នាក់មូលដ្ឋានគឺមានសារៈសំខាន់យ៉ាងខ្លាំង ដែលផ្តល់នូវចំណេះដឹងគ្រឹះដើម្បីទទួលបានការបន្តរការសិក្សានៅកម្រិតបន្តបន្ទាប់ទៀតឲ្យកាន់តែមានប្រសិទ្ធភាព និងបានឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍន៍ប្រទេស។

យ៉ាងណាមិញ ស្ថាប័នអប់រំត្រូវបានបែងចែកជាពីរប្រភេទគឺស្ថាប័នរដ្ឋ និងស្ថាប័នឯកជន។ តាមការសង្កេតទូទៅបានបង្ហាញឲ្យឃើញថា ការអប់រំរបស់ស្ថាប័នឯកជន មានការយកចិត្តទុកដាក់ជាពិសេសគឺផ្តោតសំខាន់ទៅលើការពង្រឹងវិន័យ គុណភាព និងសេវាកម្ម ព្រមទាំងបំពេញកង្វះខាតរបស់ ស្ថាប័នរដ្ឋ ដូចជាទទួលយកសិស្សដែលមិនអាចចូលសិក្សានៅសាលារដ្ឋបាន ការបំពាក់សម្ភារៈសិក្សា ទំនើបៗ និងកម្មវិធីសិក្សាក្រៅថ្នាក់ជាដើម។ កត្តានេះហើយដែលជម្រុញអោយក្រុមយើងខ្ញុំចាប់អារម្មណ៍ ទៅលើការអប់រំរបស់ សាលារៀន សុវណ្ណភូមិ ដែលជាស្ថាប័នឯកជនផ្តល់នូវសេវាអប់រំ នៅកម្រិតក្រោម ក្រោមមត្តេយ្យសិក្សា មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិមក ធ្វើការសិក្សាស្រាវជ្រាវ។

## ២. ការកំណត់បញ្ហា

ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានផ្តល់នូវធនធានមនុស្សយ៉ាងច្រើន ប៉ុន្តែធនធានមួយផ្នែកធំនៅមិនទាន់មានសមត្ថភាពសមស្រប ដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅឡើយទេ ហើយមូលហេតុដែលចម្បងសំខាន់នោះគឺដោយសារតែសិស្ស-និស្សិតជាច្រើនមិនមានមូលដ្ឋានគ្រឹះរឹងមាំនៅពេលសិក្សាថ្នាក់មូលដ្ឋាន ដែលធ្វើអោយសិស្សមិនអាចចាប់យកនូវចំណេះដឹងនៅកម្រិតថ្នាក់ឧត្តមសិក្សា និងជំនាញឯកទេសបាន ហើយនិស្សិតបញ្ចប់ថ្នាក់ឧត្តមសិក្សាភាគច្រើនមិនមានសមត្ថភាពគ្រប់គ្រាន់ សម្រាប់បំពេញការងារតាមជំនាញរបស់ខ្លួន ឬក៏ត្រូវធ្វើការខុសជំនាញសិក្សារបស់ខ្លួន។

កត្តាមួយចំនួនដែលពួកយើងចង់សិក្សាទៅលើសាលារៀន សុវណ្ណភូមិ មានដូចជា៖

- ✓ តើសាលារៀននេះបានផ្តល់សេវាអប់រំអ្វីខ្លះដល់សិស្សានុសិស្ស?
- ✓ តើការអប់រំគោរពតាមស្តង់ដាដល់កម្រិតណា?
- ✓ តើមានបញ្ហាអ្វីខ្លះដែលអាចកើតមានចំពោះការសិក្សារបស់សិស្សនៅក្នុងសាលារៀន សុវណ្ណភូមិ?
- ✓ តើសាលាមានទំនាក់ទំនងជាមួយអាណាព្យាបាលសិស្សយ៉ាងណាដែរ?

## ៣. កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវនេះគឺដើម្បីបង្ហាញពី៖

១. កត្តាដែលធ្វើអោយការអប់រំមានគុណភាព

២. សេវាដែលជាតម្រូវការ ដែលទាក់ទងនឹងការអប់រំ

៣. សកម្មភាពអប់រំរបស់សាលារៀន សុវណ្ណភូមិ

៤. សកម្មភាពរបស់សាលារៀន សុវណ្ណភូមិក្នុងសង្គម

៥. SWOT របស់សាលារៀន សុវណ្ណភូមិ

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវមានសារៈសំខាន់សម្រាប់យើងខ្ញុំ អ្នកសិក្សាក្រោយៗ និងស្ថាប័នអប់រំផ្សេងទៀត ទុកជាបទពិសោធន៍ និងវិធីសាស្ត្រក្នុងវិស័យអប់រំសម្រាប់ដកស្រង់ និងយកទៅអនុវត្តតាមភាពជាក់ ស្តែង។ សារៈសំខាន់ទាំងនោះមានដូចជា៖

- ✓ បង្ហាញពីដំណើរការវិវត្តន៍នៃប្រព័ន្ធអប់រំផ្នែកចំណេះទូទៅនៅប្រទេសកម្ពុជា

- ✓ លើកឡើងពីផែនការ និងយុទ្ធសាស្ត្រដែលទាក់ទងនឹងវិស័យអប់រំ
- ✓ ដកស្រង់នូវទ្រឹស្តី និងទស្សនៈដែលបង្ហាញពីការចូលរួម ក្នុងការអភិវឌ្ឍន៍នៃការបណ្តុះបណ្តាលធនធានមនុស្ស
- ✓ សិក្សាពីសកម្មភាពអប់រំនៃសាលារៀន សុវណ្ណភូមិ
- ✓ បទពិសោធន៍នៃការចុះកម្មសិក្សា និងការរៀបចំរបាយការណ៍កម្មសិក្សា
- ✓ ការប្រាស្រ័យទាក់ទងជាមួយស្ថាប័នរដ្ឋ និងឯកជន
- ✓ ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗ ធ្វើការស្រាវជ្រាវបន្ថែមទៀត

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងនៅសាលារៀន សុវណ្ណភូមិ សាខាបឹងត្របែកដោយផ្តោតសំខាន់ទៅលើសកម្មភាពអប់រំជាភាសាជាតិនៅក្នុងកម្រិតបឋមសិក្សាក្នុងឆ្នាំ២០១៩ ហើយធ្វើការសំភាសទិន្នន័យផ្ទាល់មាត់ដែលមានទិន្នន័យយកមកវិភាគពី ខែមករា ដល់ ខែមីនា ក្នុងឆ្នាំ ២០១៩។ ទិន្នន័យដែលប្រមូលបានគឺសរុបបញ្ចូលគ្នាក្នុងខែនីមួយៗ ហើយបង្ហាញទិន្នន័យសរុបយកមកគូសក្រាហ្វិច និង បកស្រាយទិន្នន័យទាំងអស់តើវាមានលក្ខណៈកើនឬថយពី ខែមករា ដល់ ខែមីនា ក្នុងឆ្នាំ២០១៩នេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ជាការពិតណាស់ទិន្នន័យដែលទទួលបានទាំងអស់ នៅក្នុងការស្រាវជ្រាវនេះ ត្រូវបានបែងចែកជាពីរ គឺទិន្នន័យចម្បង និង ទិន្នន័យបន្ទាប់បន្សំ។

- ទិន្នន័យចម្បង(ទិន្នន័យទី១)

  ទិន្នន័យចម្បង ជាទិន្នន័យដែលពុំទាន់មានអ្នកប្រើប្រាស់ និង ធ្វើការវិភាគនៅឡើយទេ។ ជាទិន្នន័យដែលក្រុមយើងខ្ញុំ ទទួលបានមកពីធ្វើការសម្ភាសន៍ ដោយផ្ទាល់ជាមួយនឹងលោកដែលមានតួនាទីជាអ្នកសម្របសម្រួលថ្នាក់ចំណេះទូទៅខ្មែរ ដើម្បីទទួលបានព័ត៌មានពិត និង ទិន្នន័យសម្រាប់យកមកធ្វើការវិភាគ។

- ទិន្នន័យបន្ទាប់បន្សំ (ទិន្នន័យទី២)

  ទិន្នន័យបន្ទាប់បន្សំ ដែលបានចងក្រងជាឯកសារច្បាស់លាស់រួចរាល់ជាស្រេចពោលគឺសំដៅដល់ឯកសារសំខាន់នានា ដែលសម្រាប់យកមកធ្វើជាជំនួយបន្ថែមទៀតក្នុងការស្រាវជ្រាវដោយ នៅក្នុងនោះរួមមានការប្រមូលតាមរយៈអ៊ីនធើណេតសៀវភៅតាមបណ្ណាល័យអំពីទ្រឹស្តីអប់រំជាភាសាជាតិនានា។

- ឯកសារស្តីពីគោលការណ៍ណែនាំអំពីកម្មវិធីសិក្សា ចំណេះទូទៅខ្មែរដែលបាន ចងក្រងឡើងដោយសាលារៀនសុវណ្ណភូមិក្នុងឆ្នាំ២០១៥ ប៉ុន្តែពុំទាន់មានការ វិភាគនៅឡើយ
- ឯកសារស្តីពីការតាមដាន និង ត្រួតពិនិត្យការជ្រើសរើសគ្រូបង្រៀនចំណេះ ទូទៅខ្មែរ
- ទទួលបានពីវេបសាយរបស់សាលារៀនសុវណ្ណភូមិដោយដកស្រង់នៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៩
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សារបស់រៀមច្បងនិស្សិត ទិត្យ វណ្ណៈ និង មាស ច័ន្ទតូ ឆ្នាំ ២០១១។

ទិន្នន័យទាំងអស់នេះ យើងយកទៅធ្វើការវិភាគនៅក្នុងជំពូក៣។

# ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ

## ១.១ និយមន័យអប់រំ

ការអប់រំ គឺជាការណែនាំបង្ហាត់បង្ហាញ តម្រែតម្រង់ផ្លូវដើម្បីអោយសម្រេចទៅដល់គោលដៅនៃជីវិត។ ការអប់រំ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់មនុស្សនៅទៅទាំងសាកលលោក មិនថា ប្រទេសនោះជាប្រទេសអភិវឌ្ឍន៍ កំពុងអភិវឌ្ឍន៍ ឬប្រទេសក្រីក្រនោះទេ គ្រប់មនុស្សទាំងអស់សុទ្ធតែ ត្រូវការការអប់រំជាការចាំបាច់។ ជាធម្មតាមនុស្សយើងតាំងតែពីតូចមក គឺត្រូវការការទូន្មានប្រៀនប្រដៅ ពីសំណាក់មាតាបិតា ឬអាណាព្យាបាលនូវក្រមសីលធម៌ របៀបរបបនៃការរស់នៅ រហូតដល់គ្រប់អាយុចូលរៀន មាតាបិតា ឬអាណាព្យាបាលបានបញ្ជូនទៅសាលារៀនដើម្បីស្វែងយល់ពីបរិយាកាសខាងក្រៅ ដែលជាផ្នែកមួយយ៉ាងសំខានក្នុងការអភិវឌ្ឍន៍ខ្លួនរបស់កូនពួកគាត់។ ការអប់រំបានដឹកនាំមនុស្សអោយស្គាល់នូវតម្លៃរបស់ខ្លួនឯងច្បាស់ យល់អំពីបញ្ហាដែលកើតមានឡើងនៅក្នុងសង្គមបានកាន់តែទូលំទូលាយ ព្រមទាំងមានការពិចារណាច្បាស់លាស់មុននឹងធ្វើការសម្រេចចិត្ត។ ការអប់រំ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ជាតិ។ ប្រសិនបើប្រទេសមួយប្រជាជនគ្មានការសិក្សាអប់រំបាន ខ្ពង់ខ្ពស់នោះទេ ប្រទេសនោះនឹងគ្មានការអភិវឌ្ឍន៍នោះទេ បើទោះបីជាប្រទេសនោះសម្បូរទៅដោយធនធានធម្មជាតិដើម្បីយកទៅអនុវត្តយ៉ាងណាក៏ដោយ។

តាមរយៈឯកសារច្បាប់ស្តីពីការអប់រំ ឆ្នាំទី៧ លេខ៩៣ សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៧ រាជកិច្ចទំព័រ៩៨០៥ មាត្រាទី៤ បានឲ្យនិយមន័យថា ការអប់រំគឺសំដៅដល់កិច្ចដំណើរការអភិវឌ្ឍន៍ការ សិក្សា ឬការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែល ធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឲ្យក្លាយខ្លួនជាបុគ្គលល្អ ដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។[១]

## ១.២ គោលបំណងនៃការអប់រំនៅប្រទេសកម្ពុជា

ការសិក្សាអប់រំមានគោលបំណងជម្រុញធនធានមនុស្សអោយមានកំណើនទៅមុខ ដើម្បីចូលរួមចំណែក ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ ការអប់រំជាផ្នែកមួយយ៉ាងសំខាន់ គឺដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ ប្រជាជននៅតាមទីជនបទក៏ដូចជានៅតាមទីប្រជុំជនផងដែរ។ ការអប់រំក៏ជាចំណែកមួយជួយជម្រុញឲ្យប្រជាជនស្គាល់ នូវអ្វីដែលល្អ និងអ្វីដែលអាក្រក់សម្រាប់ធ្វើការ

[១] https://data.opendevelopmentmekong.net

វិនិច្ឆ័យ។ គោលបំណងដែលធំនៅក្នុងវិស័យអប់រំនៅ ប្រទេសកម្ពុជា គឺប្រជាជនមានលទ្ធភាពក្នុងការស្តារ និងលើកស្ទួយសេដ្ឋកិច្ចជាតិ និងជាអ្នកបន្តវេន។

## ១.៣ ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

ការអប់រំជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេស ហើយនៅកម្ពុជាប្រព័ន្ធអប់រំបានក្លាយជាផ្នែកមួយដ៏សំខាន់ដែលគ្រប់ភាគីទាំងអស់ក្នុងសង្គមកំពុងយកចិត្តទុកដាក់។ ទោះបីជាមានការកែទម្រង់ ហើយភាពវិជ្ជមានក៏កំពុងកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃសម្រាប់វិស័យអប់រំនៅកម្ពុជាយ៉ាងណាក៏ដោយ តែវិសមភាពនៃការផ្តល់ឱ្យនូវចំណេះដឹង ជាពិសេសនៅតាមតំបន់ជនបទក៏នៅតែមានបញ្ហាប្រឈមជាច្រើនដែលធ្វើឱ្យវាក្លាយជាឧបសគ្គដែលរាំងស្ទះដល់ដំណើរការនៃការកសាងធនធានមនុស្ស។ អង្គការ UNICEF បានបង្ហាញក្នុងបណ្តាញសង្គមផ្លូវការរបស់ខ្លួនថា ប្រព័ន្ធអប់រំនៅកម្ពុជា ជាពិសេសគុណភាពអប់រំនៅមានកម្រិត ដែលជាមូលហេតុនាំឱ្យមានការរៀនត្រួតថ្នាក់ និងការបោះបង់ចោលការសិក្សានៅមានអត្រាខ្ពស់នៅឡើយ។ តែទោះជាយ៉ាងណាក៏ដោយក្រសួងអប់រំ ដោយមានការគាំទ្រពីសហភាពអឺរ៉ុប និងទីភ្នាក់ងារស៊ុយអែតដើម្បីអភិវឌ្ឍន៍អន្តរជាតិ រួមជាមួយអង្គការ UNICEF បានបង្កើតគម្រោងមួយឈ្មោះថា មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ ដើម្បីដោះស្រាយបញ្ហាទាំងអស់ខាងលើនោះ។ យោងតាម ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងនៅក្នុងសន្និបាតបូកសរុបការងារក្រសួងអប់រំថា បច្ចុប្បន្នការបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សាមានការថយចុះ តែសម្រាប់សិស្សនៅកម្រិតមធ្យមសិក្សា គឺនៅមានចំនួនច្រើននៅឡើយ ព្រោះពួកគេស្ថិតក្នុងវ័យដែលត្រូវចេញទៅរកប្រាក់ចំណូលជួយគ្រួសារ។[២]

### ១.៣.១ ដំណើរការវិវត្តន៍នៃប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

ជាតិការពិតណាស់ ប្រព័ន្ធអប់រំនៅប្រទេសម្ពុជាមានការប្រែប្រួលពីមួយជំនាន់ទៅមួយជំនាន់ ដោយសារតែប្រទេសយើងបានជួបនូវបញ្ហាភ្លើងសង្គ្រាម និងបញ្ហានៃការផ្លាស់របបដឹងនាំជាច្រើន សម័យកាល។ នៅក្នុងរបាយការណ៍នៃការស្រាវជ្រាវនេះ ក្រុមខ្ញុំបាទនឹងលើកយកនូវដំណើរការវិវត្តន៍នៃ ប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីសម័យអាណានិគមនិយមបារាំងរហូតមកដល់បច្ចុប្បន្ន។

- **ការអប់រំនៅសម័យអាណានិគមនិយមបារាំង**

[២] http://www.lareine.com.kh/news/education/5655/

ការសិក្សាអប់រំនៅសម័យដែលបារាំងគ្រប់គ្រងមិនសូវមានការរីកចម្រើនប៉ុន្មានទេ ប៉ុន្តែនៅពេលនោះ គេឃើញថា បារាំងបានយកប្រព័ន្ធអប់រំថ្មីមកបំពាក់បន្ថែមលើការសិក្សាអប់រំបែបប្រពៃណីរបស់ខ្មែរ។ ទន្ទឹមគ្នានេះ ការសិក្សាតាមបែបប្រពៃណី គឺការបួសរៀននៅក្នុងវត្តអារាមនានា ក៏នៅតែបន្តតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការជួយសង្គ្រោះកូនខ្មែរឱ្យបានរួចចាកផុតពីភាពអវិជ្ជា។ ចំណែកឯព្រះសង្ឃនៅតែមានតួនាទីជាគ្រូបាអាចារ្យដ៏សំខាន់ក្នុងការជួយបង្ហាត់បង្រៀននូវវប្បធម៌ ប្រពៃណី អក្សរសាស្ត្រខ្មែរដល់កូនខ្មែរនាពេលនោះដដែល។ លោក ដេវិឌ ឆាណ្ឌល័រ (២០០៥:១៦,៨) បានលើកឡើងនៅក្នុងសៀវភៅរបស់លោកថា "នៅក្នុងសម័យអាណានិគម ភាពចេះអាននិងចេះសរសេរភាសាខ្មែរស្ថិតនៅក្នុងការគ្រប់គ្រងនៃព្រះសង្ឃសឹងទាំងស្រុង"។[៣]

- **ការអប់រំនៅសម័យសង្គមរាស្ត្រនិយម**

យើងតែងតែឮការសរសើរមិនដាច់ពីមាត់របស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការខ្មែរជាច្រើន ពីការអប់រំនៅសម័យសង្គមរាស្ត្រនិយមដែលចូលរួមចំណែកយ៉ាងសំខាន់ ធ្វើឱ្យសម័យនោះមានការរីក ចម្រើនខ្លាំង។ អ្នកខ្លះធ្លាប់ឆ្លងកាត់សម័យកាលជាក់ស្តែង ចំណែកឯអ្នកខ្លះទៀតគ្រាន់តែឮ និងថាតាមគេប៉ុណ្ណោះពិសេសយុវជនជំនាន់ថ្មី ។ អ្វីដែលធ្វើឱ្យពួកគាត់មានការភ្ញាក់ផ្អើលខ្លាំងគឺ ការយកចិត្តទុកដាក់លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនរបស់រាជរដ្ឋាភិបាលនៅសម័យនោះ និងការផ្តល់ប្រាក់បៀវត្សដ៏ច្រើនសន្ធឹកសន្ធាប់។ វិជ្ជាជីវៈគ្រូបង្រៀនត្រូវបានគេចាត់ទុកថាមានកិត្យានុភាពខ្ពស់ជាងគេបំផុត និងត្រូវបានគោរពយ៉ាងខ្លាំងនៅក្នុងសង្គម។ គ្រូបង្រៀនទទួលបានការគាំទ្រពេញលេញពីរាជរដ្ឋាភិបាល និងមានគន្លងអាជីពខ្ពង់ខ្ពស់ អាចក្លាយជាឧត្តមមន្ត្រី ឬជាអ្នកនយោបាយ។ ជាមួយគ្នានេះ គេក៏បានមើលឃើញពីលទ្ធផលសិក្សារបស់សិស្ស និស្សិតប្រកបដោយគុណភាពផងដែរ។ ជាទូទៅពួកគាត់វាយតម្លៃថា សិស្ស និស្សិតបញ្ចប់ការសិក្សានៅមធ្យមសិក្សា ឬឧត្តមសិក្សាសុទ្ធតែមានសមត្ថភាពខ្ពស់ ជាធនធានដ៏មានសក្តានុពលពិតប្រាកដក្នុងការអភិវឌ្ឍប្រទេសមួយ (កំណែទម្រង់វិស័យអប់រំនៅ កម្ពុជា មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិនិងវិបុលភាព ហង់ជួនណារ៉ុង ២០១៦ ទំព័រ៧៥)។ ទិដ្ឋភាពនេះ បង្កើតឱ្យមានក្តីស្រមៃជាច្រើនសម្រាប់ប្រជាពលរដ្ឋខ្មែរ ពិសេសគ្រូបង្រៀននៅសម័យបច្ចុប្បន្ននេះ និងមានបំណងចង់ឱ្យប្រព័ន្ធអប់រំខ្មែរដូចសម័យសង្គមរាស្ត្រនិយម។

ជាការពិត គំរូនៃប្រព័ន្ធអប់រំនៅសម័យមួយវាតែងតែមានចំណុចខ្លាំង និងចំណុចខ្សោយ របស់វា។ បើយើងសម្លឹងតែជ្រុងមួយនៃទិដ្ឋភាពអប់រំនៅសម័យសង្គមរាស្ត្រនិយម យើង

[៣] https://phumisrukkhmer.wordpress.com/2012/11/12

ឃើញសុទ្ធតែចំណុចវិជ្ជមានដែលមានឥទ្ធិពលលើសលុបលើចំណុចអវិជ្ជមាន ដែលមិនសូវមានអ្នកចាប់អារម្មណ៍។ការកែទម្រង់ប្រព័ន្ធនៅសម័យមួយ វាឆ្លើយតបទៅនឹងស្ថានភាព និងតម្រូវការជាក់ស្តែងនៅសម័យនោះ។ ថ្វីត្បិតតែ វាមានចំណុចល្អជាច្រើនដូចដែលបានបង្ហាញខាងលើ តែវាក៏មានចំណុចមិនល្អមួយចំនួនផងដែរ ដែលវាមិនបានឆ្លើយតបទៅនឹងប្រព័ន្ធអប់រំនៅកម្ពុជាបច្ចុប្បន្ន និងនិន្នាការអប់រំនៅលើពិភពលោក។ ជាក់ស្តែង ប្រព័ន្ធអប់រំនៅសម័យសង្គមរាស្ត្រនិយមមានលក្ខណៈជាសាជីកំពូលស្រួច ដែលផ្តោតតែទៅលើគុណភាព ដោយមិនគិតពីសមធម៌។ ប្រព័ន្ធអប់រំនេះ ចម្រាញ់តែមនុស្សមានសមត្ថភាពខ្ពស់ ដែលធ្វើឱ្យអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់។ មានសិស្សនៅមធ្យមសិក្សាទុតិយភូមិ ៣% ប៉ុណ្ណោះដែលបានប្រឡងជាប់ និងបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។ មកដល់ពេលបច្ចុប្បន្ននេះ ប្រព័ន្ធអប់រំប្រទេសកម្ពុជា បានអនុលោមតាមការប្រព័ន្ធអប់រំមួយដែលប្រកបដោយគុណភាពផង និងសមធម៌ផង។ ដោយមើលឃើញគុណវុឌ្ឍិដ៏ត្រចេះត្រចង់ ផលប្រយោជន៍ទទួលបានរបស់គ្រូបង្រៀន និងភាពរីកចម្រើនរបស់ប្រទេសជាតិនៅសម័យនោះ ទើបម្នាក់ៗចង់អោយយុគសម័យនោះវិលត្រឡប់មកវិញម្តងទៀត។[៤]

- **ការអប់រំនៅសម័យលន់ នល់ (១៩៧០-១៩៧៥)**

ក្នុងឆ្នាំ ១៩៧០ សាកលវិទ្យាល័យជាមួយចំនួនសរុបសិស្សចុះឈ្មោះជិត ៩០០០ នាក់ជាជនជាតិកម្ពុជា។ សាកលវិទ្យាល័យភ្នំពេញដែលជាសាកលវិទ្យល័យធំជាងគេបង្អស់មានសិស្សប្រុសជិត ៩៥៧០ នាក់ និងថែមសិស្សស្រីជាង ៧៣០ ក្នុងប្រាំបី ផ្នែក មនុស្សសាស្ត្រ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ច្បាប់ និងសេដ្ឋកិច្ច ថ្នាំកែរោគ គិលានុដ្ឋាន ពាណិជ្ជសាស្ត្រ គរុកោសល និង ឧត្តមគរុកោសល។ សាកលវិទ្យាល័យបានប្រតិបត្តិក្នុងខេត្ត កំពង់ចាម តាកែវ បាត់ដំបង និង ក្នុងរាជធានីភ្នំពេញ ព្រមទាំងមានសាកលវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងសាកលវិទ្យាល័យវិចិត្រសិល្បៈ។ ក្រោយរដ្ឋប្រហារទម្លាក់របបលន់ នល់ សាកលវិទ្យាល័យនៅតាមបណ្តាខេត្តទាំង៣ ត្រូវបានបិទ។ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងអំណាចបាន វិស័យអប់រំត្រូវបានធ្លាក់ចុះយ៉ាងខ្លាំងដោយខ្មែរក្រហមបានបិទសាលាមិនអោយកូនខ្មែរបានរៀនសូត្រមានចំណេះដឹងឡើយ។

- **ការអប់រំនៅសម័យប៉ុល ពត (របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម)**

[៤] http://ousa-chao.blogspot.com/2017/06/blog-post.html

ក្នុងអតីតរបបកម្ពុជាប្រជាធិបតេយ្យ វិស័យអប់រំត្រូវគេកែប្រែ។ ការសិក្សាមានតែ ៤ថ្នាក់ប៉ុណ្ណោះ គឺថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ និងថ្នាក់ទី៤ ហើយគេមិនបាច់រៀនតទៅអនុវិទ្យាល័យ វិទ្យាល័យ ឬ សកលវិទ្យាល័យណាមួយដូចប្រទេសដទៃនានានោះឡើយ។ មតិជាច្រើនរហូតមកទល់ពេលនេះបានវាយតម្លៃថា របបខ្មែរក្រហមជារបបចង់ឲ្យកូនខ្មែរល្ងង់ ចង់ឲ្យកូនខ្មែរធ្លាក់ទន់ខ្សោយ ដោយការអនុវត្តនយោបាយហួសហេតុនៃការប្រកាន់លទ្ធិកុម្មុយនីស្តប្រទេសចិន។

អតីតគ្រូបង្រៀនម្នាក់ក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យបានរៀបរាប់ថា មូលហេតុដែលរបបខ្មែរក្រហមឲ្យការសិក្សាមានតែបួនថ្នាក់ គឺដោយសារតែធ្វើឲ្យស្របតាមភាពជាក់ស្តែង ដែលប្រទេសកំពុងជួបប្រទះនាពេលនោះ។ អតីតគ្រូបង្រៀននៃជំនាន់របបខ្មែរក្រហម លោក សៀង សាក់ ដែលបច្ចុប្បន្នកំពុងរស់នៅក្នុងសហរដ្ឋអាមេរិក បានថ្លែងថា ប៉ុល ពត បានគិតថា គេមិនចាំបាច់ឲ្យមនុស្សរៀនបានច្រើននាំតែខាតពេលវេលានោះទេ ពីព្រោះកម្ពុជាជាប្រទេសកសិកម្ម ដែលការប្រើចប ប្រើបង្គី និងការធ្វើស្រែ។

បើយោងតាមអតីតប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន ដែលសរសេរសៀវភៅមួយមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជា" លោកបានសរសេរគាំទ្រគំនិតរបស់ ប៉ុល ពត ដែលឲ្យកម្ពុជា ជំនាន់នោះរៀនតែ ៤ថ្នាក់ ដោយបញ្ជាក់ថា ការធ្វើនោះមិនមែនដើម្បីទុកឲ្យជាតិនៅល្ងង់ខ្លៅនោះទេ។

លោក ខៀវ សំផន បានថ្លែងថា ខ្មែរក្រហមបានយល់ឃើញថា វិជ្ជាចេញមកពីការជាក់ស្តែង និងថា បើគ្មានការជាក់ស្តែងទេ វិជ្ជាក៏យកទៅប្រើការអ្វីមិនបាននោះដែរ។ លោក ខៀវ សំផន និយាយទៀតថា បទពិសោធន៍ជាហូរហែ ខ្មែរក្រហមបានឃើញថា មានអ្នកបច្ចេកទេសវិទ្យាសាស្ត្រមួយចំនួន ចេញពីសកលវិទ្យាល័យ ឬពីសាលាបច្ចេកទេសជាន់ខ្ពស់នៃប្រទេសបារាំង តែអ្នកទាំងនោះ ពេល ត្រឡប់មកវិញ មិនអាចយកវិជ្ជាដែលគេបានរៀនទៅប្រើប្រាស់បានឡើយ។

លោក ខៀវ សំផន បានលើកទៀតថា ដូច្នេះកុមារនិងយុវជនជំនាន់នោះ ចាំបាច់ត្រូវយកការដ្ឋានទំនប់ប្រឡាយ យកស្រែ ធ្វើជាសាលារៀនវិញ ដើម្បីឲ្យពួកគេយល់ទាំងការជាក់ស្តែង ហើយចេះទ្រឹស្តីបណ្តើរៗ ស្របនឹងសភាពការណ៍ប្រទេសនាពេលនោះ។ លោក ខៀវ សំផន បាននិយាយទៀតថា ការទាមទារឲ្យសិស្សរៀនទ្រឹស្តីខ្ពស់ហួសកម្រិតនឹងសភាពការណ៍វិវត្តន៍ប្រទេសនឹងនាំឲ្យតែអសារឥតការ។

លោក ខៀវ សំផន បានលើកឧទាហរណ៍មួយនិយាយថា នៅឆ្នាំ ១៩៦១ សម្តេចព្រះនរោត្តម សីហនុ បានត្រូវបង្ខំចិត្តប្រកាសថា ការងាររាជការពេញអស់ហើយ ហើយមិនមានកន្លែង

សម្រាប់ទទួលសិស្សនិងនិស្សិតចំនួន ៦សែននាក់ ដែលពេលនោះកំពុងតែរៀននោះបានទេ។ លោក ខៀវ សំផន និយាយថា សម្តេចព្រះនរោត្តម សីហនុ បានអំពាវនាវសុំឲ្យពួកសិស្សនិងនិស្សិតទាំងនោះ ត្រឡប់ទៅធ្វើស្រែចម្ការនោះវិញ។

លោក ខៀវ សំផន បានបញ្ជាក់ទៀតថា ដូច្នេះបើកម្ពុជាប្រជាធិបតេយ្យដើរតាមគន្លងសិក្សាធិការចាស់នោះ វានឹងនាំឆ្ពោះទៅរកផ្លូវទ័លច្រកជាមិនខាន។ ខៀវ សំផន បានបញ្ជាក់ទៀតថា ក្រុមខ្មែរក្រហមបានរៀបចំឲ្យកុមាររៀនលេខ អក្សរ នៅតាមសហករណ៍ ជាប់នឹងស្រែ ជាប់នឹងដី ជាប់នឹងទឹក តាមទ្រឹស្តីធ្វើបណ្តើររៀនបណ្តើរពីទាបទៅខ្ពស់។[៥]

➢ **ការអប់រំនៅសម័យបច្ចុប្បន្ន**

ជាមួយនឹងប្រជាពលរដ្ឋមួយភាគបី មានអាយុក្រោម ១៥ ឆ្នាំ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានប្រជាជនក្មេងជាងគេ នៅតំបន់អាស៊ីអាគ្នេយ៍នេះ។ កុមារចំនួនប្រាំលាននាក់នាពេលបច្ចុប្បន្ននេះ មានសក្តានុពលយ៉ាងធំធេង ដើម្បីក្លាយទៅជា ប្រជាពលរដ្ឋប្រកបដោយជំនាញដែលអាចជួយរុញច្រានអនាគតកម្ពុជាឲ្យកាន់តែល្អប្រសើរ។

ក្រោយការដួលរលំរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការកសាងឡើងវិញនូវ ប្រព័ន្ធសង្គមរបស់ខ្លួន និងបង្កើតនូវប្រព័ន្ធថ្មីៗសម្រាប់ការពារអប់រំ និងផ្តល់ការទំនុកបម្រុងដល់ប្រជាពលរដ្ឋកម្ពុជា គ្រប់រូប។ ប្រទេសកម្ពុជា បានដើរលើដំណើរផ្លូវដ៏វែងឆ្ងាយចាប់ តាំងពីពេលនោះមក ជាមួយនឹងការសម្រេចបាននូវវឌ្ឍន ភាពជាច្រើន ក្នុងវិស័យអប់រំ ការរស់រានរបស់កុមារ និងការទទួលបានទឹកស្អាត។

កុមារី និងកុមារា ជាង ៩៧ ភាគរយ បានចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាដែលជាអត្រាខ្ពស់បំផុតមិនធ្លាប់មាន កន្លងមក។ កុមារដែលបាត់បង់ជីវិតមុនខួបកំណើតប្រាំឆ្នាំរបស់ពួកគេកាន់តែមានតិចជាងមុន។ ជាមួយនឹងតួលេខ ថយចុះពី ១២៤ កំណើតរស់ ក្នុង ១០០០ កំណើតក្នុងឆ្នាំ ២០០០ មកនៅ ៣៥ កំណើតរស់ក្នុង ១០០០ កំណើតក្នុងឆ្នាំ ២០១៤។ ការទទួលបានប្រភពទឹកដែលត្រូវបានកែលម្អ មានការកើនឡើងពី ២២ ភាគរយ ក្នុងឆ្នាំ ១៩៩០ ដល់ ៧០ ភាគរយ ក្នុងឆ្នាំ ២០១៧។[៦]

### ១.៣.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និង កីឡា

[៥] https://www.rfa.org/khmer/event/education-in-kr-regime-part1-05062009053127.html

[៦] https://www.unicef.org/cambodia/km

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាងនិងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីក ចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានចក្ខុវិស័យខាងលើ ក្រសួង អប់រំ យុវជន និងកីឡា មានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យអប់រំ យុវជន និងកីឡានៃ ព្រះរាជាណាចក្រកម្ពុជា ឲ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និង សកល-លោក។

វត្ថុបំណងសម្រាប់រយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនរបស់កម្ពុជាលើគ្រប់ វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឲ្យមានមោទនៈភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូប មានឱកាសស្មើគ្នាទាំងអស់ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស-និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹងមួយច្បាស់លាស់ស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ ជម្រុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ប្រទេសកម្ពុជាបានឈានចូលក្នុងដំណាក់កាលមួយថ្មីទៀតនៃការអភិវឌ្ឍវិស័យអប់រំ ដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងការអប់រំមូលដ្ឋាន និងគុណភាពសិក្សានៅក្នុងក្របខណ្ឌសេដ្ឋកិច្ចជាតិ ដែលមានលក្ខណៈជាប្រព័ន្ធដ៏ទូលំទូលាយ។ ចក្ខុវិស័យអប់រំសម្រាប់រយៈពេលវែង របស់ប្រទេសកម្ពុជា នឹងយកចិត្តទុកដាក់ផ្តល់នូវសេវាអប់រំដល់កុមារតូចតាមគ្រប់រូបភាពដែលជាមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ការអប់រំនៅកម្រិតបន្តបន្ទាប់ទៀត និងយកចិត្តទុកដាក់ដល់សិស្សានុសិស្ស នៅកម្រិតដំបូងនៃបឋមសិក្សាលើបំណិនអំណាន និងលេខនព្វន្ត។ វិស័យអប់រំនឹងពង្រីកវិសាលភាពនៃ ការអប់រំសម្រាប់ទាំងអស់គ្នាពីបឋមសិក្សា ៦ ឆ្នាំ ទៅដល់អប់រំមូលដ្ឋាន ៩ ឆ្នាំ។ សិស្សានុសិស្សដែល បញ្ចប់ការសិក្សាអប់រំមូលដ្ឋាននឹងត្រូវពិនិត្យមើលឧបនិស្ស័យ

ក្នុងការជ្រើសរើសបន្តការសិក្សានៅអប់រំ មធ្យមសិក្សាចំណេះទូទៅ ឬក៏ជ្រើសការអប់រំបច្ចេកទេសវិជ្ជាជីវៈ។ ការលើកកម្ពស់គុណភាពនៃការអប់រំ ក៏ត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុដែលរួមបញ្ចូលមាន ដំណើរការរៀន និងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូលនឹងផ្តោតសំខាន់លើគុណវុឌ្ឍិគ្រូបង្រៀន ដែលនឹងត្រូវបង្កើន រូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤ នៅឆ្នាំ ២០២០។ គុណភាពរបស់កម្មវិធីសិក្សានៅអប់រំ ចំណេះទូទៅ និងឧត្តមសិក្សាឱ្យស្របទៅនឹងគុណភាពស្តង់ដាអាស៊ាន។

**១.៣.៣ យុទ្ធសាស្ត្រ និង ផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ**

ការធ្វើសមាហរណកម្មនៅក្នុងសមាគមន៍អាស៊ានឆ្នាំ ២០១៨ និងការប្រែក្លាយកម្ពុជាឱ្យក្លាយទៅ ជាប្រទេសមានចំណូលមធ្យមឆ្នាំ ២០៣០ ទាមទារឱ្យមានការវិយោគបន្ថែមទៀតទៅលើវិស័យអប់រំ។ ធនធានមនុស្សដែលមានវិជ្ជាជីវៈត្រឹមត្រូវ និងមានគុណភាព ព្រមទាំងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ក៏ត្រូវដាក់ចូលវិស័យអប់រំផងដែរ (ប្រទេសក្នុងអាស៊ានដែលជោគជ័យ ក៏ទទួលបានបទពិសោធពីការបង្កើនការវិនិយោគនៅក្នុងវិស័យអប់រំ ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប)។

ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ពីសារៈសំខាន់ក្នុងការជំរុញឱ្យវិស័យទាំងមូលអាចធ្វើ ការជាមួយគ្នា ដើម្បីឆ្លើយតបនឹងតម្រូវការសង្គម និងសេដ្ឋកិច្ច។ ផែនការយុទ្ធសាស្ត្រនៅក្នុងវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ផ្តោតលើការពង្រឹងសមិទ្ធិផលដែលមានកន្លងមក ការឈានទៅដល់ក្រុមដែលជួបការ លំបាក ការផ្តល់ការអប់រំប្រកបដោយគុណភាព និងភាពឆ្លើយតបសម្រាប់ការអភិវឌ្ឍប្រទេស។ ការផ្តល់ សេវាអប់រំ ប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាព ជាមូលដ្ឋានសម្រាប់ការកសាងសង្គមមួយប្រកប ដោយចំណេះដឹង និងជំនាញ។ វិស័យអប់រំនឹងរៀបចំនូវក្របខណ្ឌធានាគុណភាពទូទាំងវិស័យ ដោយ ផ្អែកលើស្តង់ដារនៃការសិក្សារៀនសូត្រ និងការផ្តល់សេវាដែលឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ សហគមន៍ និងទីផ្សារការងារ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំនឹងឈរលើមូលដ្ឋាននៃការគ្រប់គ្រង និងការកសាងផែនការថវិកា ផ្តោតលើលទ្ធផលនឹងត្រូវរៀបចំតាមអនុវិស័យសំខាន់ៗ ៧ ដូចជាការអប់រំកុមារតូចការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា។

ការងាររបស់អនុវិស័យទាំងនេះរួមបញ្ចូលទាំងការអភិវឌ្ឍន៍គ្រូបង្រៀន ការកែលម្អនូវកម្មវិធីសិក្សាថ្មី និងសម្ភាររៀន និងបង្រៀន ការរៀបចំក្របខណ្ឌធានាគុណភាព ការអភិវឌ្ឍបែបវិមជ្ឈការ និង វិសហាវិមជ្ឈការដែលគាំទ្រដោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស។[៧]

### ១.៣.៤ កម្មវិធីសិក្សាជាតិ

ក្រសួងអប់រំ យុវជន និង កីឡា បានរៀបចំឡើងវិញនូវចំណុចមួយចំនួនក្នុងកម្មវិធីសិក្សាគោលឆ្នាំ ១៩៩៦ ដូចជាការសម្រួលរបាយម៉ោងសិក្សា ការផ្តល់ការអប់រំបំណិនជីវិតក្នុងកម្មវិធីបំណិនជីវិត តាមមូលដ្ឋាន និងបន្ថែមម៉ោងសិក្សាសម្រាប់មុខវិជ្ជានីមួយៗ ។

- **ថ្នាក់ទី ១-៣**

កម្មវិធីសិក្សាអប់រំមូលដ្ឋានកម្រិតបឋមសិក្សា ថ្នាក់ទី១-៣ គឺមានគោលបំណងធានាថាសិស្សម្នាក់ៗយល់ដឹងពីមូលដ្ឋានគ្រឹះផ្នែកភាសាខ្មែរ និង គណិតវិទ្យា ព្រមទាំងបានអភិវឌ្ឍសុខភាព កាយសម្បទា សីលធម៌ បំណិនសិក្សា និង បំណិនជិវិតផ្សេងៗ។ (សូមមើលឧបសម្ព័ន្ធទី១)

- **ថ្នាក់ទី៤-៦**

កម្មវិធីសិក្សាអប់រំមូលដ្ឋានកម្រិតបឋមសិក្សា ថ្នាក់ទី៤-៦ គឺផ្តោតទៅលើការពង្រឹង និងពង្រីកចំណេះដឹង ព្រមទាំងឱ្យសិស្សចេះធ្វើការងារជាក្រុមក្រោមការគ្រប់គ្រង និង សំយោគពីគ្រូដើម្បីឱ្យពួកគាត់ទទួលនូវចំណេះដឹងផ្នែកភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ បំណិនសិក្សា មុខវិជ្ជាសិក្សាសង្គម និងការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈដែលអាចឱ្យសិស្សបន្តការសិក្សាពេញមួយជីវិតបាន។

## ១.៥ លក្ខខណ្ឌបើកសាលារៀនចំណេះទូទៅឯកជន

ជាមួយនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងវិសយអប់រំ ការអនុវត្តន៍ក៏មានចំណាងយ៉ាងស្អិតរមួតជងដែរទៅនឹងការបង្កើតគោលនយោបាយ ផែនការ និង យុទ្ធសាស្ត្រ ដើម្បីឆ្លើយតបយ៉ាងល្អទៅនឹងគុណភាព ដូចជាសមត្ថភាព ការប្រកួតប្រជែងរបស់គ្រូបង្រៀន ការគាំទ្រវិជ្ជាជីវៈ សម្ភារឧបទ្ទេសសមស្រប និង គ្រប់គ្រាន់ ទំហំថ្នាក់រៀន និងម៉ោងបង្រៀន។ល។ ការផ្តល់ឱ្យសិស្សទាំងបរិយាកាស និងទីតាំងសិក្សាដ៏សមស្របមួយ ធ្វើឱ្យការសិក្សាកាន់តែមានប្រសិទ្ធិភាព ទាំងគុណភាព និង បរិមាណ។

ជាក់ស្តែងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំបានកំណែទម្រង់លើប្រព័ន្ធអប់រំជាច្រើនទាក់ទងនឹងការកែប្រព័ន្ធប្រឡង និងសមត្ថភាពគ្រូផ្សេងៗ ក្នុងន័យមួយថា នៅពេល

[៧] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ទំព័រ១៥-១៦ ជំពូកទី២

ណាដែលប្រទេសយើងកំពុងស្ថិតនៅដំណាក់កាលប្រកួតប្រជែង ទាំងរដ្ឋទាំងឯកជនត្រូវតែប្រឹងទាំងអស់គ្នា ។ អ្វីដែលកត់សម្គាល់មួយទៀត រដ្ឋនិងឯកជន ហាក់ដូចជាចាប់ដៃគ្នាប្រកួតប្រជែងក្នុងន័យគោលដៅរួមគ្នា មិនមែនប្រកួតប្រជែងដើម្បីឈ្នះចាញ់ទេ តែជានាបានគុណភាពនៅថ្ងៃអនាគត ។[៨]

លើសពីនេះទៅទៀត ការបន្តពង្រឹងភាពជាដៃគូ រវាងផ្នែកសាធារណៈ និង ផ្នែកឯកជនក្នុងការកៀងគរ និង ប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពថែមទៀត ដើម្បីសម្រេចជោគជ័យក្នុងកំណែទម្រង់ វិស័យអប់រំ។[៩] ដូច្នេះហើយមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញបានកំណត់នូវលក្ខខណ្ឌមួយចំនួនក្នុងការបើកសាលារៀនចំណេះទូទៅឯកជនដូចខាងក្រោម៖

➢ **ទីតាំង**

- ប្រសិនបើទីតាំងជួលគេ ត្រូវធ្វើលិខិតសុំជួល ដែលទទួលស្គាល់ដោយសាលាក្រុងភ្នំពេញ ហើយម្ចាស់ផ្ទះត្រូវបង់១០% នៃតម្លៃឈ្នួលជូនរដ្ឋ ។ តែបើទីតាំងជាកម្មសិទ្ធផ្ទាល់ខ្លួន ឬ របស់ឪពុកនោះមិនចាំបាច់មានលិខិតដូចខាងលើទេ។
- ត្រូវមានកន្លែងដាក់យានជំនិះ របស់សិស្សដែលមិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ

➢ **ការបំពេញបែបបទ**

សាលាចំណេះទូទៅឯកជនត្រូវបំពេញបែបបទសំណុំលិខិតរបស់មន្ទីរអប់រំ យុវជន និង កីឡាដែលមានដូចខាងក្រោម៖

- ពាក្យសុំ
- បញ្ជីរាយនាមសម្ភារក្នុងសាលា
- បញ្ជីរាយនាមគ្រូ និង នាយក (ភ្ជាប់ជាមួយប្រវត្តិរូប និង សញ្ញាបត្រថតចម្លង)
- កិច្ចសន្យារវាងសាលា និង មន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ
- លិខិត និង ប្លង់បំព្រួញបញ្ជាក់ទីតាំង
- ប្រកាសទុន ដោយភ្ជាប់លិខិតបញ្ជាក់ពីធនាគារណាមួយនៅក្នុងរាជធានីភ្នំពេញ
- កម្មវិធី និងកាលវិភាគសិក្សា។

[៨] លោក ឃឹម ផុន នាយកប្រតិបត្តិអ៊ិន ធី ស៊ីគ្រុប បានផ្តល់នូវបទសម្ភាសន៍ ជាមួយអ្នកយកព័ត៌មានផ្នែកសេដ្ឋកិច្ច (Kb) របស់កោះសន្តិភាព(ឆ្នាំ២០១៥) ។
[៩] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-២០១០, ទំព័រ១

ឯកសារទាំងអស់ត្រូវផ្គុំគ្នា ហើយយកឆ្លងសង្កាត់ ខណ្ឌគោលដៅនៃច្រកចេញ-ចូលតែមួយតាមទីតាំងរបស់ខ្លួន ការិយាល័យអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញ និងក្រសួងអប់រំ យុវជន និង កីឡាដែលចេញប្រកាសឱ្យដំណើរការជាអចិន្ត្រៃយ៍។

ករណីសាលាឯកជនណាមួយដែលមិនមានអាជ្ញាប័ណ្ណអប់រំ ឬលិខិតអនុញ្ញាតដែលចេញពីក្រសួងអប់រំ យុវជន និង កីឡា គឺនឹងមានការទទួលពិន័យអន្តរការណ៍ជាប្រាក់។ (សូមមើលឧបសម្ព័ន្ធទី១)។

គ្រប់សាលាត្រូវគោរពតាមគោលការណ៍ណែនាំរបស់មន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញក្នុងការអនុវត្តន៍កម្មវិធីសិក្សា និងចូលរួមប្រឡងថ្នាក់ជាតិ។

ចំពោះកម្រិតថ្នាក់មត្តេយ្យ កម្រិតបឋម និងកម្រិតមធ្យមសិក្សា(ថ្នាក់ទី ៧, ៨ ,១០ និងទី ១១) ការប្រឡងឆមាសគឺសាលាសាមីជាអ្នកចេញវិញ្ញាសាប្រឡង។ រីឯថ្នាក់ទី៩ និង ថ្នាក់ទី១២ វិញ្ញាសាចេញដោយក្រសួងអប់រំ យុវជន និង កីឡា ហើយសិស្សសាលាចំណេះទូទៅឯកជន ត្រូវទៅចូលរួមប្រលងជាមួយសិស្សសាលារដ្ឋតាមត្រកូលនៃអក្សរនីមួយៗ។

បញ្ជាក់៖

- ឈ្មោះសាលានឹងមិនប៉ះពាល់ជាមួយសាលាដទៃ
- សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ របស់សិស្សសាលាចំណេះទូទៅឯកជនមានតម្លៃដូចគ្នា នឹងសាលារដ្ឋដែរ។
- ចំពោះការផ្ទេរការសិក្សា សិស្សអាចផ្ទេរពីសាលារដ្ឋទៅសាលាឯកជន ឬ ពីសាលាឯកជនទៅសាលារដ្ឋបាន។

## ១.៥ ប្រព័ន្ធអប់រំនៅបណ្តាលប្រទេសកំពុងអភិវឌ្ឍមួយចំនួន

ជាមួយនឹងចំណេះដឹងដ៏ធំល្វឹងល្វើយគ្មានដែនកំណត់ ទំនៀមទម្លាប់ វប្បធម៌ និង ប្រវត្តិសាស្ត្រ ដែលមានលក្ខណៈខុសគ្នារបស់ប្រទេសនីមួយៗ បានធ្វើឱ្យការរៀបចំនូវប្រព័ន្ធអប់រំក៏មានលក្ខណៈខុសគ្នាមួយចំនួនដែរ។ លើសពីនេះទៅទៀត សូម្បីតែប្រទេសកំពុងអភិវឌ្ឍដូចគ្នានឹងប្រទេសកម្ពុជាក៏មានប្រព័ន្ធអប់រំផ្សេងគ្នាផងដែរ គ្រាន់តែគោលបំណងនៃការអប់រំគឺសុទ្ធសឹងតែដើម្បីអភិវឌ្ឍធនធានដែលជាចលករនៃកម្លាំងសេដ្ឋកិច្ច ក៏ដូចជាការអភិវឌ្ឍន៍ប្រទេសជាតិ។ ដូច្នេះហើយ ក្រុមយើងខ្ញុំសូមលើកយកប្រព័ន្ធអប់រំ របស់ប្រទេសកំពុងអភិវឌ្ឍមួយចំនួនមកបង្ហាញដូចខាងក្រោម៖

### ១.៥.១ ប្រព័ន្ធអប់រំក្នុងប្រទេសវៀតណាម

ប្រព័ន្ធអប់រំនៅថ្នាក់មូលដ្ឋានបែងចែកជា ៤ គឺ ៖

- មត្តេយ្យសិក្សា មានរយៈពេល ៣ ឆ្នាំ (ចាប់ពីអាយុ៣ឆ្នាំ)
- បឋមសិក្សា មានរយៈពេល ៥ឆ្នាំ (ពីអាយុ ៦ ដល់ ១១ឆ្នាំ)
- មធ្យមសិក្សាបឋមភូមិ មានរយៈពេល ៤ឆ្នាំ ( ពីអាយុ ១១ ដល់ ១៥ឆ្នាំ)
- មធ្យមសិក្សាទុតិយភូមិ មានរយៈពេល ៣ ឆ្នាំ ( ពីអាយុ ១៥ ដល់ ១៨ឆ្នាំ)

សរុបមកការអប់រំថ្នាក់មូលដ្ឋាននៅប្រទេសវៀតណាម មានរយៈពេល ១២ឆ្នាំ។[១០]

### ១.៥.២ ប្រព័ន្ធអប់រំក្នុងប្រទេសឡាវ

ប្រព័ន្ធអប់រំនៅថ្នាក់មូលដ្ឋានត្រូវបានបែងចែកជា៥ គឺ៖ ថ្នាក់ក្រោមមត្តេយ្យ ថ្នាក់មត្តេយ្យ ថ្នាក់បឋមសិក្សា ថ្នាក់មធ្យមសិក្សាកម្រិតទាប និងថ្នាក់មធ្យមសិក្សាកម្រិតខ្ពស់។ ហើយកម្រិតនីមួយៗមានរយៈពេលសិក្សាដូចខាងក្រោម៖

- ថ្នាក់ក្រោមមត្តេយ្យសិក្សារយៈពេល ៣ ឆ្នាំ(អាយុ ១ ទៅ ៣ឆ្នាំ)
- ថ្នាក់មត្តេយ្យសិក្សារយៈពេល ៣ឆ្នាំ (អាយុ ៤ ទៅ ៦ឆ្នាំ)
- ថ្នាក់បឋមសិក្សាត្រូវសិក្សារយៈពេល ៥ឆ្នាំ ពីថ្នាក់ទី ១ ដល់ ថ្នាក់ទី ៥ (អាយុ ៧ ទៅ១១ឆ្នាំ)
- ថ្នាក់មធ្យមសិក្សាកម្រិតទាបសិក្សារយៈពេល ៣ ឆ្នាំពីថ្នាក់ទី៦ ដល់ថ្នាក់ទី ៨ ( អាយុ ១២ ទៅ ១៤ ឆ្នាំ)
- ថ្នាក់មធ្យមសិក្សាកម្រិតខ្ពស់សិក្សារយៈពេល ៣ ឆ្នាំពីថ្នាក់ទី៩ ដល់ថ្នាក់ទី ១១ ( អាយុ ១៥ ទៅ ១៧ ឆ្នាំ)

បើសិនជាមិនរាប់បញ្ចូលថ្នាក់ក្រោមមត្តេយ្យ និង ថ្នាក់មត្តេយ្យទេនោះ ការសិក្សាបញ្ចប់ថ្នាក់មធ្យមសិក្សាកម្រិតខ្ពស់មានរយៈពេល ១១ឆ្នាំ។[១១]

### ១.៥.៣ ប្រព័ន្ធអប់រំក្នុងប្រទេសមីយ៉ាន់ម៉ា

ប្រព័ន្ធអប់រំនៅក្នុងប្រទេសមីយ៉ាន់ម៉ាគឺ ពឹងផ្អែកទៅលើប្រព័ន្ធអប់រំរបស់ប្រទេសអង់គ្លេស ហើយប្រព័ន្ធអប់រំថ្នាក់មូលដ្ឋានគឺត្រូវបានបែងចែកជាបួន គឺថ្នាក់ក្រោមមត្តេយ្យ ថ្នាក់បឋមសិក្សា ថ្នាក់មធ្យមសិក្សាបឋមភូមិ ថ្នាក់មធ្យមសិក្សាទុតិយភូមិ។

[១០] http://vovworld.vn/vi-VN.vov (Vietnam Education , ដកស្រង់ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៩)

[១១] http://factsanddetails.com/southeast-asia/Laos/sub5_3d/entry-2981.html (Laos Education System, ដកស្រង់ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៩)

- ថ្នាក់ក្រោមមត្តេយ្យមានរយៈពេល ១ឆ្នាំ (ពីអាយុ ៤ ទៅ ៥ឆ្នាំ)
- ថ្នាក់បឋមសិក្សាមានរយៈពេល ៥ឆ្នាំ ពីថ្នាក់ទី១ ដល់ទី ៥ (ពីអាយុ ៦ដល់ ១១ឆ្នាំ)
- ថ្នាក់មធ្យមសិក្សាបឋមភូមិ ត្រូវចំណាយការសិក្សារយៈពេល ៤ ឆ្នាំ ពីថ្នាក់ទី៦ ដល់ទី ៩ (ពីអាយុ ១២ ដល់ ១៦ឆ្នាំ)
- ថ្នាក់មធ្យមសិក្សាទុតិយភូមិ សិក្សារយៈពេល ២ ឆ្នាំ ពីថ្នាក់ទី ១០ដល់ ១១ (ចាប់ពីអាយុ ១៧ ដល់ ១៩ឆ្នាំ)។[១២]

## ១.៦ សេចក្តីសន្និដ្ឋានក្នុងជំពូកទ្រឹស្តី

តាមរយៈការលើកឡើងពីទ្រឹស្តី ក្នុងការអប់រំ និង ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និង ក្រសួងពាក់ព័ន្ធ បានបង្ហាញពីការអប់រំមូលដ្ឋាន និង ភាពជាដៃគូជាមួយឯកជន ជាពិសេសការយកចិត្តទុកដាក់ទាំងការពង្រឹង និង ការបំពេញភាពខ្វះខាតនៅក្នុងវិស័យអប់រំ។ ដូចនេះ វត្តមាននៃសាលាចំណោះទូទៅឯកជន មានលក្ខណៈអំណោយផលចំពោះប្រទេសកម្ពុជាក្នុងការលើកស្ទួយគុណភាពក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្ស។

[១២] https://www.scholaro.com/pro/Countries/myanmar/Education-System (Myanmar Education Systemដកស្រង់ថ្ងៃទី ១៦ ខែមិថុនា ឆ្នា ២០១៩)

# ជំពូកទី២ ស្ថានភាពទូទៅនៅសាលារៀន សុវណ្ណភូមិសាខាបឹងត្របែក

## ២.១ ប្រវត្តិនៃសាលារៀនសុវណ្ណភូមិបឹងត្របែក

សាលារៀនសុវណ្ណភូមិ គឺជាសាលាចំណេះទូទៅឯកជនមួយក្នុងចំណោមសាលាចំណេះទូទៅឯកជនផ្សេងៗទៀតរបស់ អ៊ិន ធី ស៊ី គ្រុប ដែលបានធ្វើការបង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ ២០០៩ ក្រោមគំនិតផ្តួចផ្តើមរបស់លោក ឧកញ៉ា ជា ធីឡាយ អគ្គនាយក អ៊ិន ធី ស៊ី គ្រុប ដែលមានទីតាំងសរុបចំនួន២៥កន្លែង និងមានសិស្សានុសិស្សកំពុងសិក្សាសរុបប្រហែលជាង៣៥០០០នាក់ ទូទាំងប្រទេស។ សាលារៀន សុវណ្ណភូមិ ជាស្ថាប័នអប់រំឯកជនមួយដែលមានបើកបង្ហាត់បង្រៀននូវចំណេះដឹងទូទៅខ្មែរ និង ភាសាអង់គ្លេស ថ្នាក់មត្តេយ្យ ថ្នាក់បឋមសិក្សា (ថ្នាក់ទី១ដល់ទី៦) និងកម្រិតមធ្យមសិក្សា (ថ្នាក់ទី៧ដល់ទី១២)។

មូលហេតុចំបងដែលជម្រុញឲ្យមានការបង្កើតឡើងនូវសាលាចំណេះទូទៅឯកជននេះ គឺដោយសារតែ ស្ថាបនិករបស់ អ៊ិន ធី ស៊ី គ្រុប លោក ឧកញ៉ា ជា ធីឡាយ បានបង្កើតសាលាចំណេះទូទៅញ៉ូតុនធីឡាយ នៅអំឡុងឆ្នាំ ១៩៩៦ ដោយទទួលបាន ជោគជ័យ រួចម្តងទៅហើយ។ ញ៉ូតុន ធីឡាយបានដំណើរការមកដល់ឆ្នាំ២០០៩ ដោយកត្តាប្រកួតប្រជែងខ្លាំង NTC Group ក៏បានចាប់ផ្តើមពង្រីកសាខាបន្ថែមទៀត ដោយបានបង្កើតឈ្មោះសាលារៀនចំណេះទូទៅថ្មីថា «សាលារៀន សុវណ្ណភូមិ »។ ការបង្កើតសាលារៀនសុវណ្ណភូមិនេះ NTC Group ចង់បង្កើតសាលារៀនមួយដែលមានឈ្មោះជារបស់ខ្មែរ បង្ហាញជាលក្ខណៈខ្មែរ ហើយយើងនឹងធ្វើវាឲ្យដើរដោយលក្ខណៈ ស្តង់ដា ព្រមទាំងឱ្យខ្មែរយើងដឹងថាសាលារៀនឈ្មោះជាខ្មែរក៏មានខ្មែរគាំទ្រដែរ។ គោលដៅដែលលោកឧកញ៉ាបង្កើតសាលារៀនសុវណ្ណភូមិ គឺលោកចង់បញ្ជាក់ថាថ្នាក់ដឹកនាំនៅទីនេះសុទ្ធតែជាខ្មែរ ម្ចាស់ស្ថាប័ននេះក៏ជាខ្មែរហើយយើងចង់ឲ្យសាលារៀនបែបខ្មែរមួយនេះល្បីនៅក្នុងស្រុកខ្មែរ។

ដើម្បីបំពេញតាមសេចក្តីត្រូវការរបស់អតិថិជន សាលាបានធ្វើការអភិវឌ្ឍខ្លួនជាបន្តបន្ទាប់ទាំងផ្នែកធនធានមនុស្ស ធនធានសម្ភាររូបវន្ត ធ្វើទំនើបកម្មកម្មវិធីសិក្សាទៅលើកម្មវិធីដែលមានស្រាប់ និងយកចិត្តទុកដាក់ទៅលើបរិស្ថានសិក្សា ដោយផ្តោតសំខាន់ទៅលើគុណភាពក្នុងការសិក្សារបស់សិស្សានុសិស្ស។

ដោយមានការទទួលស្គាល់គុណភាពអប់រំ ផ្នែកចំណេះទូទៅភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងមានការជឿទុកចិត្តពីសំណាក់មាតាបិតាសិស្សទាំងនៅរាជធានីភ្នំពេញ ព្រម

ទាំងបណ្តាលខេត្តមួយចំនួនផងនោះ ធ្វើឲ្យកំណើនសិស្សមានការកើនឡើងជាលំដាប់ ជាហេតុធ្វើឲ្យសាលារៀនសុវណ្ណភូមិបានពង្រីកនូវ សាខាថ្មីជាបន្តបន្ទាប់ទៀតរហូតមកដល់សព្វថ្ងៃនេះ។ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៨ សាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក ក៏បានបើកបវេសនកាលថ្មី ដើម្បីបំពេញនូវតម្រូវការនៃកំណើនសិស្ស នៅក្នុងតំបន់នេះ។ ហើយនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៩ សាលារៀននេះក៏បានធ្វើពិធីសម្ពោធជាផ្លូវការដោយមានការចូលរួមពីគណ:គ្រប់គ្រងនៅសាលារៀនសុវណ្ណភូមិ គ្រប់សាខាក្នុងរាជធានីភ្នំពេញ។ សាខានេះគឺជាសាខាដែល ពង្រីកក្រោយគេបង្អស់ក្នុងចំណោមសាខាទាំង២៧ ទូទាំងប្រទេស។ (មើលឧបសម្ព័ន្ធទី២)

សាលារៀនសុវណ្ណភូមិគឺជាស្ថាប័នអប់រំមួយ ក្នុងចំណោមស្ថាប័នអប់រំផ្សេងៗទៀតរបស់ អ៊ិន ធី ស៊ី គ្រុប ដែលបានបង្កើតឡើង ក្នុងគោលបំណងសំខាន់ៗចំនួន៣គឺៈ

- រួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា។
- ចែករំលែកបទពិសោធន៍ និងចំណេះដឹងផ្នែកអប់រំ ជូនប្អូនៗសិស្សានុសិស្សគ្រប់មជ្ឈដ្ឋានដែលពួកគាត់ចាំបាច់ត្រូវតែទទួលបាន នូវការអប់រំមួយប្រកបដោយគុណភាពពិតប្រាកដ។
- បង្កើតទីផ្សារការងារបន្ថែម ជូនបុគ្គលិកគ្រូបង្រៀន បុគ្គលិករដ្ឋបាល និងបុគ្គលិកផ្សេងៗទៀត អោយពួកគាត់មានឱកាសការងារ ជាមួយសាលារៀនសុវណ្ណភូមិ។

## ២.២ ទីតាំងនៃសាលារៀន សុវណ្ណភូមិ បឹងត្របែក

សាលារៀន សុវណ្ណភូមិ បឹងត្របែកមានទីតាំងស្ថិតនៅក្នុងខណ្ឌចំការមន សង្កាត់បឹងកេងកង៣ រាជធានីភ្នំពេញ ដែលមានអគារចំនួន១១ជាន់។

## ២.៣ ផ្លាកសញ្ញា

និមិត្តសញ្ញានៃសាលារៀន សុវណ្ណភូមិ គឺមានការសរសេរអក្សរពណ៌ស ជាខេមរភាសានៅខាងលើដោយដាក់ថា "សាលារៀន សុវណ្ណភូមិ" និងសរសេរជាភាសាបរទេសនៅខាងក្រោមថា ( Sovannaphum School)។ ផ្លាកសញ្ញានេះរំលេចដោយពណ៌ក្រហមនៅខាងក្នុង ពណ៌ខៀវនៅជុំវិញខាងក្រៅ នៅខ្សែរង្វង់អមដោយពណ៌លឿង បែកទឹកក្រូច។(មើលឧបសម្ព័ន្ធទី៣)

## ២.៤ ចក្ខុវិស័យ និងបេសកកម្ម

### ២.៤.១ ចក្ខុវិស័យ

សិស្សានុសិស្សទទួលបានជោគជ័យក្នុងការសិក្សា ការងារ ជីវិត និងក្លាយជាធនធានមនុស្ស ដែលមានសមត្ថភាព ពិតប្រាកដមួយនៅក្នុងសង្គម។

### ២.៤.២ បេសកកម្ម

ដើម្បីសំរេចបាននូវចក្ខុវិស័យខាងលើនេះ សាលារៀនសុវណ្ណភូមិ បានកំណត់នូវបេសកកម្មសំខាន់ៗចំនួន៤ដូចតទៅ:

- **ផ្តល់នូវកម្មវិធីសិក្សាដែលមានគុណភាព៖** ដើម្បីអោយសិស្សមានការអភិវឌ្ឍន៍ផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ និងវប្បធម៌។
- **ផ្តល់ជូននូវគ្រូបង្រៀនដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់៖** ធ្វើអោយសិស្សមានការរីកចំរើនទៅលើការសិក្សានៅក្នុងថ្នាក់រៀន និងសកម្មភាពផ្សេង។
- **ផ្តល់ជូននូវបរិយាកាសល្អក្នុងការសិក្សា៖** សិស្សានុសិស្សទាំងអស់ ត្រូវបានជំរុញ និងលើកទឹកចិត្តរាល់សមិទ្ធិផល និងស្នាដៃផ្សេងៗដែលពួកគេសំរេចបាន។
- **ផ្តល់ជូននូវសម្ភារឧបទ្ទេសគ្រប់គ្រាន់** ៖សម្ភារឧបទ្ទេសទាំងអស់ ត្រូវបានធានាអោយមានទៅតាមកំរិតសិក្សានីមួយៗ ធ្វើយ៉ាងណាដើម្បីអោយការសិក្សារបស់សិស្ស មានភាពរីកចំរើនទៅមុខជានិច្ច។

ការសំរេចបាននូវចក្ខុវិស័យ របស់សាលារៀនសុវណ្ណភូមិ កើតចេញពីការខិតខំប្រឹងប្រែងទាំងកំលាំងកាយ កំលាំងចិត្ត និងកំលាំងប្រាជ្ញា របស់គណៈគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ លោកគ្រូ-អ្នកគ្រូ បុគ្គលិកគ្រប់ផ្នែក និងមានការចូលរួមយ៉ាងសកម្មពីសំណាក់មាតាបិតា ឬអាណាព្យាបាលសិស្ស។

## ២.៥ រចនាសម្ព័ន្ធគ្រប់គ្រងនៃសាលារៀន សុវណ្ណភូមិ បឹងត្របែក

ដើម្បីឱ្យសាលារៀនមានដំណើរការបានល្អប្រកបដោយគុណភាព ប្រសិទ្ធភាព និងមានការរីកចំរើនទៅមុខ គឺត្រូវមានអ្នកដឹកនាំមួយដ៏ល្អ និងមានការបែងចែកការងារទៅតាមផ្នែកនីមួយៗឱ្យបានច្បាស់លាស់។ (មើលឧបសម្ព័ន្ធទី៨)

## ២.៦ សកម្មភាពអប់រំនៃសាលារៀន សុវណ្ណភូមិបឹងត្របែក

តាមការសម្ភាសន៍ផ្ទាល់ជាមួយលោក ម៉ុម ហាញ ទទួលបន្ទុកកិច្ចការខាងសម្របសម្រួលថ្នាក់ចំណេះទូទៅខ្មែរបានឱ្យដឹងថា សាលារៀន សុវណ្ណភូមិសាខាបឹងត្របែក បានឈរលើគោលជំហរបី ដើម្បីជម្រុញវិស័យអប់រំ គឺគុណភាព វិន័យ និង សេវាកម្ម ដែលឆ្លុះបញ្ចាំងតាមសកម្មភាពដូចខាងក្រោម៖

### ២.៦.១ លក្ខខណ្ឌចូលរៀន

ដើម្បីចុះឈ្មោះចូលរៀននៅសាលារៀន សុវណ្ណភូមិ សិស្សត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដែលជាតម្រូវការរបស់ក្រសួងអប់រំ យុវជន និង កីឡា និង ជាតម្រូវការរបស់សាលា ដែលក្នុងនោះមានដូចជា៖

- ❖ លក្ខខណ្ឌរបស់សាលារៀន
  - សិស្សថ្នាក់មត្តេយ្យភាសាខ្មែរ៖ សិស្សត្រូវមានអាយុចាប់ពី៣ឆ្នាំ ដល់ ៥ឆ្នាំ គិតដល់ថ្ងៃចូលរៀន។
  - សិស្សថ្នាក់បឋមសិក្សា៖ សិស្សត្រូវមានអាយុចាប់ពី ០៦ ឆ្នាំ ឬយ៉ាងតិច ៧០ខែ គិតដល់ថ្ងៃចូលរៀន
  - សិស្សថ្នាក់មធ្យមសិក្សា៖ សិស្សត្រូវមានអាយុចាប់ពី ១២ ឆ្នាំឡើងទៅ គិតដល់ថ្ងៃចូលរៀន។
- ❖ ដំណាក់កាលនៃការធ្វើតេស្ត

  ការវាយតម្លៃទៅលើសមត្ថភាពរបស់សិស្សដែលទើបនឹងចូលថ្មីមានការចែកជា២ផ្នែកគឺ៖
  - ផ្នែកចំណេះទូទៅខ្មែរ៖ ត្រូវធ្វើសំណួរសរសេរចំនួន ២មុខវិជ្ជាគឺគណិតវិទ្យា និងភាសាខ្មែរដោយត្រូវប្រើរយៈពេលមួយម៉ោងក្នុងមួយមុខវិជ្ជាដើម្បីរៀបចំសិស្សទៅតាមកម្រិតថ្នាក់ឲ្យសមស្របទៅនឹងសមត្ថភាពរបស់ពួកគេ។
  - ផ្នែកភាសាបរទេស៖ ធ្វើសំណួរសរសេរចំនួនមួយម៉ោងនិងធ្វើការសម្ភាសន៍ចំនួនដប់ប្រាំនាទីរវាងគ្រូជំនាញ និងអាណាព្យាបាលរបស់សិស្ស និងសិស្សដើម្បីឲ្យអាណាព្យាបាលបានដឹងពីសមត្ថភាពភាសាអង់គ្លេសរបស់សិស្ស ព័ត៌មានទាក់ទងនឹងសាលា ការសហការរវាងសាលា និងអាណាព្យាបាល និងវិធីក្នុងការតាមដានការសិក្សារបស់សិស្ស។
- ❖ ក្រោយពេលធ្វើតេស្ត

  ក្រោយបញ្ចប់ពីការធ្វើតេស្ត ការសម្ភាសន៍ និងការសម្រេចចិត្តពីអាណាព្យាបាលឲ្យសិស្សចូលរៀន សាលានឹងកំណត់ឲ្យអាណាព្យាបាលសិស្សរៀបចំនូវឯកសារមួយចំនួនដែលទាក់ទងនឹងសិស្សមានដូចជា៖
  - ចំពោះសិស្សថ្មី ៖ សេចក្តីចម្លងបញ្ជាក់កំណើត រូបថត៤×៦ចំនួន៤សន្លឹក ៣×៤ចំនួន២សន្លឹក កិច្ចសន្យាប្តូរអាយុ (ករណីខ្វះអាយុ) ពាក្យសុំចូលរៀនដែល

បំពេញរួច សៀវភៅសិក្ខាគារិក(សាលាសាមី) សៀវភៅតាមដានការសិក្សា (សាលារៀនសុវណ្ណភូមិ) កិច្ចសន្យាខ្វះឯកសារ(ករណីមិនគ្រប់គ្រាន់) សៀវភៅតាមដាន(សាលាសាមី) លិខិតផ្ទេរការសិក្សា កិច្ចសន្យាសៀវភៅសិក្ខាគារិក សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ(បញ្ជាក់ពីសាលារាជធានី ឬសាលាខេត្ត) កិច្ចសន្យាសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ(បើខ្វះ)កិច្ចសន្យាស្ម័យរិន(សិស្សធ្លាក់ទី៩)។

- ចំពោះសិស្សចាស់៖ សេចក្តីចម្លងបញ្ជាក់កំណើត រូបថត៤×៦ចំនួន៤សន្លឹក ៣×៤ចំនួន២សន្លឹក កិច្ចសន្យាប្តូរអាយុ (ករណីខ្វះអាយុ) ពាក្យសុំចូលរៀនដែលបំពេញរួច
  សៀវភៅតាមដានការសិក្សា (សាលារៀនសុវណ្ណភូមិ) កិច្ចសន្យាខ្វះឯកសារ(ករណីមិនគ្រប់គ្រាន់) សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ(បញ្ជាក់ពីសាលារាជធានី ឬសាលាខេត្ត) កិច្ចសន្យាស្ម័យរិន(សិស្សធ្លាក់ទី៩)។

## ២.៦.២ កម្មវិធីសិក្សា

សាលារៀន សុវណ្ណភូមិបានបែងចែកភូមិសិក្សានៃការអប់រំជាបួនដូចខាងក្រោម៖

- មត្តេយ្យសិក្សា
- បឋមសិក្សា
- មធ្យមសិក្សាបឋមភូមិ
- មធ្យមសិក្សាទុតិយភូមិ។

❖ **ម៉ោងសិក្សាប្រចាំថ្ងៃ**

សាលារៀន សុវណ្ណភូមិ បឹងត្របែក បានរៀបចំនូវកម្មវិធីសិក្សាដែលសមស្របទៅនឹងកម្មវិធីសិក្សារបស់សាលារដ្ឋ ដែលនេះជាលក្ខខណ្ឌកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ រីឯម៉ោងសិក្សា សាលារៀនធ្វើការបែងចែកដូចខាងក្រោម៖

- ថ្នាក់មត្តេយ្យ និងបឋមសិក្សា
  - ម៉ោង៖ ៧:០០ - ១១:០០ ឬ ១:០០ - ៥:០០
  - ថ្ងៃ ៖ ចន្ទ - សុក្រ
- ថ្នាក់មធ្យមសិក្សា ទី៧ដល់ទី១២
  - ម៉ោង៖ ៧:០០ - ១១:០០ ឬ ១:០០ - ៥:០០
  - ថ្ងៃ ៖ ចន្ទ - សៅរ៍ ។

❖ បរិមាណសិស្សក្នុងថ្នាក់នីមួយៗ

ដើម្បីធានានូវប្រសិទ្ធភាពនៃការផ្តល់ចំណេះដឹង និងការគ្រប់គ្រងរបស់លោកគ្រូ អ្នកគ្រូទៅលើសិស្សានុសិស្សក្នុងថ្នាក់ សាលាបានកំណត់នូវចំនួនសិស្សនៅក្នុងថ្នាក់នីមួយៗដូចខាងក្រោម៖

- ថ្នាក់មត្តេយ្យ និងបឋមសិក្សាមានសិស្សអតិបរមាចំនួន២៥នាក់ក្នុងមួយថ្នាក់។
- ថ្នាក់មធ្យមសិក្សាទី៧ដល់ទី១២ មានសិស្សអតិបរមាចំនួន ៣៥នាក់ក្នុងមួយថ្នាក់។

❖ កម្មវិធីសិក្សាក្នុងថ្នាក់

ចំពោះកម្មវិធីសិក្សារបស់សាលារៀន សុវណ្ណភូមិទីតាំងបឹងត្របែក ពីថ្នាក់មត្តេយ្យរហូតដល់ ថ្នាក់ទី១២ គឺត្រូវបានរៀបចំ និងកំណត់ឲ្យសិក្សាដូចទៅនឹងសាលារដ្ឋដែលជាគោលការណ៍របស់ក្រសួង អប់រំ យុវជន និងកីឡា ដោយមានការចូលរួមបង្រៀនពីលោកគ្រូ អ្នកគ្រូដែលមានគុណកោសល្យ មានសមត្ថភាព និងបទពិសោធន៍ខ្ពស់ ព្រមទាំងមានបន្ថែមនូវកម្មវិធីសិក្សាមួយចំនួនទៀតដូចខាងក្រោម៖

- ថ្នាក់មត្តេយ្យសិក្សា
    - មានកម្មវិធីសិក្សាបែបសកម្មភាព បូកផ្សំនឹងមេរៀន (សិស្សមជ្ឈមណ្ឌល) ដើម្បីធ្វើឲ្យសិស្សមានការលូតលាស់ទាំងរូបរាងកាយ សម្បទា បញ្ញាស្មារតី និងចង់ពង្រឹងសមត្ថភាពមូលដ្ឋានរបស់ក្មេងសម្រាប់ការចាប់យកចំណេះដឹង នៅពេលសិស្សចូលរៀនថ្នាក់ទី១។
    - ការបង្រៀនក៏បូកបញ្ចូលទាំងការអប់រំផ្នែកសុជីវធម៌ សីលធម៌ និងបង្កើតទម្លាប់ល្អដល់ក្មេងទៀតផង។
- បឋមសិក្សា(ថ្នាក់ទី១-៦)
    - មានសិក្សាទៅលើមុខវិជ្ជាបន្ថែមដូចជា កីឡា កុំព្យូទ័រ គេហកិច្ច និង បំណិនជីវិតជាដើម។
    - ចំពោះមេរៀននៅក្នុងថ្នាក់(ថ្នាក់ទី៤-៦) ក៏មានការបញ្ចូលបន្ថែមទៅលើការសិក្សាសៀវភៅមេរៀន «អំពើពុករលួយ» ដើម្បីជួយបណ្តុះការគិតរបស់សិស្សឲ្យកាន់តែទូលំទូលាយជាងមុន។
- ថ្នាក់មធ្យមសិក្សា (ពីថ្នាក់ទី៧-១២)
    - មានមុខវិជ្ជាកុំព្យូទ័រដែលជាជម្រើសនៃការសិក្សារបស់សិស្ស។

- លក្ខណៈពិសេសមួយទៀតគឺសកម្មភាពនៃការពិសោធន៍ ដែលត្រូវបានរៀបចំឡើងនៅក្នុងម៉ោងសិក្សារបស់សិស្ស (មុខវិជ្ជាដែលត្រូវពិសោធន៍) ហើយសាលាមានទំនួលខុសត្រូវក្នុងការរៀបចំនូវសម្ភារ ឯកសារ និងការពិសោធន៍របស់សិស្ស ព្រមទាំងមានបន្ទប់សម្រាប់ឲ្យសិស្សធ្វើការពិសោធន៍ទៀតផង។

❖ **កម្មវិធីសិក្សាក្រៅថ្នាក់**

ការសិក្សាតែនៅក្នុងថ្នាក់គឺមិនទាន់គ្រប់គ្រាន់សម្រាប់ការយល់ដឹងរបស់សិស្សនោះឡើយ ដូចនេះហើយសាលាក៏បានរៀបចំនូវកម្មវិធីការសិក្សាក្រៅថ្នាក់មួយចំនួនដើម្បីផ្សារភ្ជាប់ទ្រឹស្តីដែលបានសិក្សាក្នុងថ្នាក់ទៅនឹងការអនុវត្តន៍ជាក់ស្តែង ព្រមទាំងជួយជម្រុញការយល់ដឹងបន្ថែមដល់សិស្សដូចជា៖

- ទស្សនកិច្ចសិក្សា៖ ធ្វើឡើងក្នុងគោលបំណងឲ្យសិស្សសិក្សាស្វែងយល់បន្ថែមពីមេរៀនក្នុងសាលា ទៅនឹងការអនុវត្តន៍ជាក់ស្តែងនៅតាមតំបន់នានា។
- ការតាំងពិព័រណ៍ស្នាដៃសិស្ស៖ ដែលធ្វើឡើងសម្រាប់តែថ្នាក់ទី៧-១២ ប៉ុណ្ណោះ និងក្នុងគោលបំណងឲ្យសិស្សបានបញ្ចេញនូវចំណេះដឹង ចំណេះធ្វើ ដែលបានសិក្សានៅក្នុងមេរៀន ដើម្បីបង្ហាញទៅដល់សិស្ស លោកគ្រូ អ្នកគ្រូ សាលា ព្រមទាំងភ្ញៀវ មកពីសាលាដទៃ និង អាណាព្យាបាលសិស្សដែលបានចូលរួម។ ជាក់ស្តែងការតាំងពិព័រណ៍នេះ បានបង្ហាញពីការពិសោធន៍ផ្នែកគីមីវិទ្យា រូបវិទ្យាជីវវិទ្យា ការសម្តែងឈុតរឿងអប់រំខ្លីៗ របាំ ក្បាច់រាំ និងមានជាវត្ថុអនុស្សាវរីយ៍ផ្សេងៗទៀត ដែលសិស្សបានបង្កើតឡើងដោយផ្ទាល់ដៃពួកគេ។ សកម្មភាពនេះបានផ្តល់ឱកាសឱ្យសិស្សមានគំនិតច្នៃប្រឌិត និងការបង្កើតថ្មីរបស់សិស្សដែលជាសមិទ្ធផលកើតចេញពីគំនិតរូបារម្មណ៍ ទឹកដៃ បច្ចេកទេស ទេពកោសល្យ បទពិសោធន៍ និងកិច្ចខិតខំ ប្រឹងប្រែងរៀនសូត្ររបស់ពួកគេកន្លងមក។

# ជំពូកទី៣៖ សកម្មភាពអប់រំថ្នាក់បឋមសិក្សាជាភាសាជាតិរបស់សាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក ក្នុងឆ្នាំ២០១៩

## ៣.១ ផ្នែកអប់រំ

ការអប់រំដែលមាននៅក្នុងសាលារៀនសុវណ្ណភូមិ សាខាបឹងត្របែកនេះមានគោលការណ៍ និងលក្ខខណ្ឌស្របទៅតាមក្រសួងអប់រំ យុវជន និង កីឡានៃព្រះរាជាណាចក្រកម្ពុជា។

### ៣.១.១ លក្ខខណ្ឌចូលរៀន

សាលារៀនសុវណ្ណភូមិ បានកំណត់គោលការណ៍ក្នុងការជ្រើសរើសសិស្ស ចូលសិក្សាដោយគោរពតាមគោលការណ៍ របស់ក្រសួងអប់រំ យុវជន និង កីឡា។ បន្ថែមលើគោលការណ៍នេះ សាលាបានកំណត់លក្ខខណ្ឌជ្រើសរើស ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ និង សាសនាឡើយ។

#### ៣.១.១.១ កម្រិតអាយុសិស្ស

- មានអាយុគ្រប់តាមច្បាប់ស្តីពីការអប់រំរបស់ក្រសួងអប់រំ យុវជន និង កីឡា ចាប់ពីអាយុ៦ឆ្នាំ ឬយ៉ាងទាបបំផុត ៧០ខែឡើងទៅ ទើបអាចចូលរៀនថ្នាក់ទី១បាន និងមានឯកសារបញ្ជាក់ពីកម្រិតសមត្ថភាពត្រឹមត្រូវតាមថ្នាក់។

#### ៣.១.១.២ ការធ្វើតេស្តកំណត់កម្រិតសិក្សា

- ករណីសិស្សផ្ទេរការសិក្សាពីសាលាសាធារណៈ(រដ្ឋ) ឬក៏សាលាឯកជនដែលមានអាជ្ញាបណ្ណអប់រំ គឺត្រូវធ្វើតេស្តចូលរៀនទោះបីសិស្សនោះគ្រប់អាយុ ឬលើសនិងមានឯកសារគ្រប់គ្រាន់ក៏ដោយ។
- សិស្សអនុញ្ញាតឱ្យរៀនបានតាមកម្រិតថ្នាក់ដែលបានស្នើសុំ លុះត្រាតែសិស្សនោះបានឆ្លងកាត់ការធ្វើតេស្តតាមកម្រិតថ្នាក់ដែលត្រូវចូលរៀន។
- ប្រសិនបើសិស្សធ្វើតេស្តមិនជាប់កម្រិតសិក្សា ដែលសិស្សបានស្នើសុំរៀនទេនោះ គឺ មិនអនុញ្ញាតឱ្យរៀនកម្រិតថ្នាក់នោះទេ ត្រូវថយមួយកម្រិតថ្នាក់។

ករណីដែលផ្ទុយនឹងលក្ខខណ្ឌ ដែលបានកំណត់ខាងលើនេះ លុះត្រាតែមានការព្រមព្រៀងពីសាលា និងមាតាបិតា ឬអាណាព្យាបាលសិស្ស។

#### ៣.១.១.៣ នីតិវិធីក្នុងការចុះឈ្មោះសិស្ស

សិស្សចុះឈ្មោះចូលរៀនត្រូវ៖

- បំពេញរាល់ព័ត៌មាននៅលើពាក្យសុំចូលរៀន និងចុះហត្ថលេខាពីមាតាបិតា ឬអាណាព្យាបាលសិស្ស។
- បិទរូបថតអាណាព្យាបាលសិស្ស និង រូបថតសិស្ស
- ភ្ជាប់សៀវភៅគ្រួសារថតចម្លង និងសំបុត្រកំណើតថតចម្លងរបស់សិស្ស
  ករណីផ្ទេរការសិក្សាត្រូវភ្ជាប់សំណុំឯកសារផ្ទេរដូចខាងក្រោម៖
- ករណីផ្ទេរការសិក្សាពីថ្នាក់ទី១ ដល់ថ្នាក់ទី៣ ត្រូវមានសៀវភៅតាមដានការសិក្សា លិខិតបញ្ជាក់ការសិក្សា និង លិខិតផ្ទេរការសិក្សា
- ចំពោះការផ្ទេរការសិក្សាពីថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ត្រូវមានសៀវភៅតាមដានការសិក្សា សៀវភៅសិក្ខាគារិក លិខិតបញ្ជាក់ការសិក្សា និងលិខិតផ្ទេរការសិក្សា។

បញ្ជាក់៖ ក្នុងករណីមាតាបិតា ឬអាណាព្យាបាលសិស្សមិនផ្តល់ឯកសារតាមការកំណត់ដល់សាលា គណៈគ្រប់គ្រងសាលារក្សាសិទ្ធិមិនដាក់បញ្ចូលឈ្មោះសិស្ស ចូលក្នុងបញ្ជីរាយនាមសិស្សជាផ្លូវការឡើយ។

### ៣.១.២ កម្មវិធីសិក្សា

សម្រាប់កម្មវិធីសិក្សាចំណេះទូទៅខ្មែរ របស់សាលារៀនសុវណ្ណភូមិ ត្រូវបានរៀបចំឡើងដោយស្របតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។ ជាងនេះទៅទៀត សាលាមានបន្ថែមកម្មវិធីសិក្សា និងសកម្មភាពផ្សេងៗទៀតទៅលើកម្មវិធីដែលមានស្រាប់មួយចំនួនដើម្បីផ្តល់ឱ្យសិស្សយ៉ាងសំបូរបែប ព្រមទាំងជម្រុញផ្នែកបញ្ញា ស្មារតី រាងកាយ និង ការកម្សាន្តរួមគ្នាសម្រាប់សិស្សានុសិស្សនៅកម្រិតបឋមសិក្សាដូចជា ការសិក្សាពីសីលធម៌រស់នៅ ការទំនាក់ទំនង ទស្សនកិច្ចសិក្សា និង មុខវិជ្ជាបំណិនជីវិតផ្សេងៗទៀត ។ សិស្សានុសិស្សក៏អាចទទួលបាននូវអារម្មណ៍ជឿជាក់លើសមត្ថភាពខ្លួន ដោយឆ្លងតាមកម្មវិធីសិក្សាល្អ មានទំនាក់ទំនងល្អជាមួយគ្រូបង្រៀនសមាជិកគ្រួសារ មិត្តភក្តិ និង សាលារៀន។

កម្មវិធីសិក្សានៅក្នុងកម្រិតបឋមសិក្សាមានការបែងចែកជា២ គឺសកម្មភាពរៀនក្នុងថ្នាក់ និងសកម្មភាពរៀនក្រៅថ្នាក់ដូចជា:

- ❖ កម្មវិធីសិក្សាក្នុងថ្នាក់
  - មុខវិជ្ជាដែលស្របតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និង កីឡា ទាំង ៨មុខវិជ្ជា
  - មានសិក្សាទៅលើមុខវិជ្ជាបន្ថែមដូចជា កីឡា កុំព្យូទ័រ គេហកិច្ច និង បំណិនជីវិតជាដើម។

- ចំពោះមេរៀននៅក្នុងថ្នាក់(ថ្នាក់ទី៥-៦) ក៏មានការបញ្ចូលបន្ថែមទៅលើការសិក្សាសៀវភៅមេរៀន «អំពើពុករលួយ» ដើម្បីជួយបណ្តុះការគិតរបស់សិស្សឲ្យកាន់តែទូលំទូលាយជាងមុន។(មើលឧបសម្ព័ន្ធទី៥)

❖ កម្មវិធីសិក្សាក្រៅថ្នាក់

សកម្មភាពសិក្សានៅក្នុងថ្នាក់តែមួយមុខគឺមិនទាន់ផ្តល់ចំណេះដឹង ចំណេះធ្វើគ្រប់គ្រាន់សំរាប់សិស្សានុសិស្សនៅក្នុងកម្រិតបឋមសិក្សានោះទេ គឺត្រូវមានការសិក្សាស្វែងយល់ពីចំណេះដឹងខាងក្រៅដែលទាក់ទងជាមួយនឹងមេរៀនក្នុងសៀវភៅ នៅឯសាលារៀនបន្ថែមទៀត។ កម្មវិធីសិក្សាក្រៅថ្នាក់ដែលសាលារៀនសុវណ្ណភូមិ បានធ្វើការរៀបចំឡើងដើម្បីជាការជម្រុញការយល់ដឹងបន្ថែមដល់សិស្សានុសិស្សនៅក្នុងកម្រិតបឋមសិក្សាមានដូចជា៖

- ទស្សនកិច្ចសិក្សា: ធ្វើឡើងក្នុងគោលបំណងផ្សារភ្ជាប់នូវទ្រឹស្តីនៅក្នុងសាលាទៅនឹងការអនុវត្តន៍ជាក់ស្តែង។ លើសពីនេះទៅទៀត សិស្សក៏អាចសង្កេតឃើញការរស់នៅរបស់ប្រជាពលរដ្ឋតាមតំបន់នានា ស្គាល់នូវតំបន់ប្រវត្តិសាស្ត្រ និងទេសចរណ៍នានា និង បង្កើតការចេះស្រឡាញ់ដល់បរិស្ថាន ព្រមទាំងរួមចំណែកក្នុងការថែរក្សាសម្បត្តិទាំងនេះ។ ដូចនេះហើយ សាលារៀនរៀបចំដំណើរទស្សនកិច្ចសិក្សាទៅតាមកម្រិតសិក្សារបស់សិស្ស និងធ្វើឡើងឱ្យសមស្របទៅតាមពេលវេលាដោយមិនប៉ះពាល់ដល់ម៉ោងសិក្សាក្នុងថ្នាក់របស់សិស្ស។ កន្លងមកសាលារៀនសុវណ្ណភូមិសាខាបឹងត្របែក បានរៀបចំដំណើរទស្សនកិច្ចសិក្សាជាច្រើនទៅកាន់តំបន់ទេសចរណ៍ធម្មជាតិ វប្បធម៌ និង ទស្សនកិច្ចសិក្សាវិទ្យាសាស្ត្រដែលមិនត្រឹមតែផ្តល់នូវចំណេះដឹងដល់សិស្ស ព្រមទាំងបានរឹតចំណងសិស្ស និងសិស្ស សិស្ស និង គ្រូ ហើយក៏ជួយសម្រាលភាពតានតឹង និង ជម្រុញដល់ការខិតខំប្រឹងប្រែងក្នុងការសិក្សាបន្ទាប់ពីទស្សនកិច្ចសិក្សាទៀតផង។ (មើលឧបសម្ព័ន្ធទី៦)

### ៣.១.៣ សម្ភារឧបទេសសិក្សា

នៅក្នុងដំណើរការបង្រៀន និង រៀនក្នុងកម្រិតបឋមសិក្សាគឺសិស្សទាំងអស់កំពុងតែស្ថិតនៅក្នុងវ័យកុមារភាពដែលជាវ័យមានបម្រុងប្រយ័ត្នគិតជាមធ្យមត្រឹមតែ២០នាទីប៉ុណ្ណោះ។ ហេតុដូចនេះហើយ រាល់ការបង្រៀនភាគច្រើនគឺត្រូវមានសម្ភារឧបទេសជាជំនួយបន្ថែមដើម្បីជួយ

សម្រួលដល់ការបង្រៀនរបស់គ្រូ និង ធ្វើឱ្យសិស្សកាន់តែយល់ច្បាស់ថែមទៀតផង។ ជាមួយគ្នានេះផងដែរ សាលារៀនសុវណ្ណភូមិក៏បានបង្កើត និងទិញនូវសម្ភារផ្សេងៗដែលទាក់ទងជាមួយនឹងការបង្រៀនទៅតាមកម្រិតថ្នាក់នីមួយៗដូចជា៖

- ❖ ថ្នាក់ទី១-៣៖ មានការប្រើប្រាស់នូវវត្ថុជាក់ស្តែង អក្សរចល័ត លេខចល័ត បណ្ណពាក្យ ព្រមទាំងផ្ទាំងរូបភាពផ្សេងៗទៅតាមមេរៀននីមួយៗ។
- ❖ ថ្នាក់ទី៤-៦៖ ភាគច្រើនគឺប្រើប្រាស់នូវផ្ទាំងរូបភាព បណ្ណលំហាត់ ចំណោទ និង ជាពិសេសនោះគឺមានការពិសោធន៍ច្រើនទៅលើមេរៀនវិទ្យាសាស្ត្រ ដោយយកសម្ភារពិតជាក់ស្តែងព្រមជាមួយនឹងឧបករណ៍ពិសោធន៍មកផ្ទាល់តែម្តង។

រាល់សម្ភារឧបទ្ទេសមួយចំនួនត្រូវបានផ្តល់ជូនពីខាងគណៈគ្រប់គ្រងសាលារៀន និង មួយចំនួនទៀតត្រូវបានផលិតដោយផ្ទាល់ពីសំណាក់លោកគ្រូ អ្នកគ្រូតាមកម្រិតថ្នាក់នីមួយៗ។

**៣.១.៤ បណ្ណាល័យ**

បណ្ណាល័យ គឺជាផ្នែកមួយយ៉ាងសំខាន់របស់សាលារៀន សុវណ្ណភូមិសាខាបឹងត្របែកដែលបានផ្តល់នូវឯកសារ ចំណេះដឹង និងព័ត៌មានជាច្រើនដែលជួយជម្រុញដល់ការសិក្សារបស់សិស្សបន្ថែមទៀតផង។ នៅក្នុងសាលារៀនសុវណ្ណភូមិ សាខាបឹងត្របែកមានបន្ទប់បណ្ណាល័យចំនួនមួយដែលស្ថិតនៅជាន់ទី៥ ជាប់ជាមួយនឹងបន្ទប់វីដេអូ ហើយអនុញ្ញាតឱ្យសិស្សចូលអានសៀវភៅនៅម៉ោង ៧:០០-១១:០០ និង ម៉ោង ១៣:០០-១៧:០០ ។ នៅក្នុងបណ្ណាល័យ គឺមានបណ្ណារក្សមួយដែលគាត់មានតួនាទី៖

- ❖ ត្រួតពិនិត្យ និងថែរក្សាសៀវភៅក្នុងបណ្ណាល័យមិនឱ្យខូច និង បាត់បង់
- ❖ ស្វែងរកនូវសៀវភៅថ្មីៗដែលជាចំណេះដឹងថ្មីសម្រាប់សិស្សអាន
- ❖ រក្សាសណ្តាប់ធ្នាប់ក្នុងបណ្ណាល័យ
- ❖ សម្រួលដល់ការខ្ចីសៀវភៅរបស់សិស្ស
- ❖ ត្រួតពិនិត្យ អ្នកដែលចូលអានសៀវភៅ និង អនុវត្តតាមវិន័យរបស់បណ្ណាល័យ។

ចំពោះសៀវភៅទាំងអស់ ដែលមាននៅក្នុងបណ្ណាល័យគឺជាការទិញ និង អំណោយពីខាងសហរដ្ឋអាមេរិក គណៈគ្រប់គ្រង បុគ្គលិក សិស្ស ជាដើម។ នៅក្នុងបណ្ណាល័យនេះគឺមាន៦០%ជាសៀវភៅភាសាជាតិ និង ៤០%ជាភាសាអង់គ្លេស ដែលសៀវភៅទាំងអស់នេះគឺមានទៅតាមកម្រិតថ្នាក់នីមួយៗពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់ទី១២ ។ នៅក្នុងម៉ោងសិក្សាថ្នាក់បឋមជាភាសាជាតិ គឺមានបញ្ចូលទាំងម៉ោងបណ្ណាល័យដោយ១អាទិត្យ សិក្សា១ម៉ោង គឺត្រូវមានការដឹកនាំពីគ្រូ

បន្ទុកថ្នាក់ ដើម្បីជាជំនួយដល់សិស្សរៀនយឺត។ ក្រៅពីម៉ោងសិក្សានេះ សិស្សក៏អាចចូលអានសៀវភៅនៅម៉ោងទំនេរទៀតផងដែរដោយមានការមើលខុសត្រូវពីខាងបណ្ណារក្ស ហើយសិស្សដែលមានសិទ្ធិចូលអានសៀវភៅនៅក្នុងបណ្ណាល័យបាន គឺជាសិស្ស និងអ្នកដែលជាសមាជិកបណ្ណាល័យសាលារៀន សុវណ្ណភូមិសាខាបឹងត្របែក។

យោងទៅតាមការសង្កេតរបស់បណ្ណារក្សនៃសាលារៀន សុវណ្ណភូមិ សាខាបឹងត្របែកបានបង្ហាញឱ្យឃើញថា មានសិស្សជាមធ្យមប្រហែលជា ៨០ នាក់ក្នុងមួយថ្ងៃដែលបានចូលទៅអានសៀវភៅនៅក្នុងបណ្ណាល័យ។

**៣.១.៥ វិន័យ**

ដើម្បីធ្វើឱ្យការសិក្សាកាន់តែមានគុណភាព និងវិន័យល្អដែលមានលក្ខណៈស្តង់ដាអន្តរជាតិបានលុះត្រាតែសាលារៀនមានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និង គ្រូមានបទពិសោធន៍ គរុកោសល្យខ្ពស់និង យកចិត្តទុកដាក់ក្នុងការបង្រៀន ឯសិស្សានុសិស្សក៏ត្រូវប្រកាន់ខ្ជាប់នូវវិន័យ សីលធម៌ល្អ និងការឧស្សាហ៍ព្យាយាមរៀនសូត្រផងដែរ។ យោងតាមបុព្វហេតុនេះ ដើម្បីសម្រេចតាមទិសដៅ និងប្រសិទ្ធិភាពអប់រំ សាលារៀនសុវណ្ណភូមិ សាខាបឹងត្របែកបានដាក់ចេញនូវបទបញ្ជាផ្ទៃក្នុង និងការពិន័យទុកឱ្យសិស្សានុសិស្សអនុវត្តតាម ដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

**ក.ម៉ោងសិក្សា**

- ចូលរៀនឱ្យបានទៀងទាត់ និងទាន់ពេលវេលាចាប់ពីថ្ងៃ ចន្ទ ដល់ ថ្ងៃសុក្រ
  - ពេលព្រឹក៖ ពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១១:០០នាទី
  - ពេលរសៀល៖ ពីម៉ោង ១:០០ នាទី ដល់ម៉ោង ៥:០០នាទី
  - បើសិនជាយឺតចាប់ពី ១៥នាទី ទៅត្រូវទៅសុំលិខិតអនុញ្ញាតពីការិយាល័យកិច្ចការសិស្ស។
- ចូលរួមគោរពទង់ជាតិរៀងរាល់ព្រឹកថ្ងៃចន្ទ និង ពេលល្ងាចថ្ងៃសុក្រតាមការកំណត់របស់សាលា។

**ខ.វិន័យ និង សីលធម៌**

- ហាមជក់បារី សេពគ្រឿងញៀន គ្រឿងស្រវឹង លេងល្បែងស៊ីសង យកអាវុធគ្រប់ប្រភេទ និងនាំមិត្តភក្តិពីក្រៅចូលបរិវេនសាលាដោយគ្មានការអនុញ្ញាត។
- ហាមធ្វើសកម្មភាព ឬ សម្តីព្រហើន និង មានរូបភាពស្នេហានៅក្នុងថ្នាក់ និង បរិវេណរបស់សាលា។

- ហាមបង្កើតបក្សពួកបងតូចបងធំ ក្រុមក្មេងទំនើង រើសអើងវណ្ណៈ ជាតិសាសន៍ និងពណ៌សម្បុរ
- ហាមស៊ីសំណូកសូកប៉ាន់ និងប្រព្រឹត្តិអំពើពុករលួយគ្រប់រូបភាព។
- ហាមមើលសៀវភៅរឿងអាសអាភាស និងប្រព្រឹត្តិអំពើអាសអាភាសផ្សេងៗ ក្នុងបរិវេណសាលា
- រក្សាសណ្តាប់ធ្នាប់ និងវិន័យនៅក្នុងបរិវេណសាលានៅពេលរៀនសូត្រ ពេលចេញលេង និងចេញទៅផ្ទះ។
- មិនត្រូវចេញពីបន្ទប់ពេលកំពុងរៀន ដោយគ្មានការអនុញ្ញាតពីលោកគ្រូ អ្នកគ្រូ។
- ត្រូវក្រោកឈរ និងគោរពសំពះដោយទឹកមុខរីករាយ និងស្ងៀមស្ងាត់ ហើយអង្គុយចុះវិញពេល មានភ្ញៀវ ឬគ្រូបង្រៀនចេញ ឬចូលថ្នាក់រៀន។
- ចេះគោរពមាតាបិតា ចាស់ព្រឹទ្ធាចារ្យ លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រង និងមិត្តរួមថ្នាក់ព្រមទាំងសាលារៀន។
- ត្រូវរាយការណ៍ដល់គ្រូប្រចាំថ្នាក់ សន្តិសុខ ឬអ្នកគ្រប់គ្រងនៅពេលមានបញ្ហា និងឧបទ្ទវហេតុ ផ្សេងៗកើតឡើង។
- ត្រូវយកវត្ថុដែលរើសបានទៅប្រគល់អោយការិយាល័យកិច្ចការសិស្ស ដោយមិនត្រូវមានចេតនា យកសម្ភារអ្នកដទៃមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ។

**គ.សម្លៀកបំពាក់ ការតុបតែងខ្លួន និងអនាម័យ**

ដើម្បីកំណត់នូវអត្តសញ្ញាណសិស្ស រក្សាសុវត្ថិភាពសណ្តាប់ធ្នាប់នៅក្នុងសាលា និងការពារការបន្លំចូលពីសិស្សសាលាផ្សេង ឬក៏អ្នកផ្សេង សាលារៀន សុវណ្ណភូមិ បានកំណត់នូវឯកសណ្ឋាន

សិស្សដែលមានលក្ខណៈដូចខាងក្រោម៖

- សិស្សប្រុសៈ ខោពណ៌ប្រផេះ អាវពណ៌សដែលមានផ្លាកសញ្ញាសុវណ្ណភូមិលើអាវផ្នែកខាងឆ្វេង
- សិស្សស្រីៈ សំពត់ពណ៌ប្រផេះ អាវពណ៌សដែលមានផ្លាកសញ្ញាសុវណ្ណភូមិលើអាវផ្នែកខាងឆ្វេង និងមានជាយដៃអាវពណ៌ក្រហមក្រមៅ
- កាតសម្គាល់ខ្លួនរបស់សាលារៀន សុវណ្ណភូមិ ។(មើលឧបសម្ព័ន្ធទី៧)

យ៉ាងណាមិញ សាលាក៏បានហាមប្រាមការស្លៀកពាក់ និងពិន័យដូចខាងក្រោម៖

- ហាមប្រទ្បេះទ្បេះអាវ មួរ ឬពន្លាដៃអាវ ឬពាក់មួកក្នុងបរិវេណសាលា។
- ត្រូវស្លៀកពាក់ឯកសណ្ឋានសាលា និងប័ណ្ណសម្គាល់ខ្លួនឲ្យបានសមរម្យក្នុងបរិវេណសាលា។
- សិស្សប្រុសកាត់សក់ខ្លីអោយបានសមរម្យ សិតវែកចំហៀង និងមិនលាបពណ៌សក់ លេង ម៉ូតសក់ និងពាក់ក្រវិលជាដើម។
- សិស្សស្រីប្រើដង្កៀប ក្រង ឬចងសក់ឲ្យបានសមរម្យ និងមិនផាត់ម្សៅ លាបក្រែម លាបក្រចក ឬពាក់ចង្រ្កង់ជើងឡើយ និងមិនលាបពណ៌សក់ ឬលេងម៉ូតសក់។
- មិនត្រូវពាក់គ្រឿងអលង្ការ ឬសម្ភារមានតម្លៃមកសាលារៀន ក្នុងករណីបាត់បង់សាលាមិន ទទួលខុសត្រូវឡើយ។
- ត្រូវថែរក្សាទ្រព្យសម្បត្តិរួម (តុ កៅអី អំពូលភ្លើង ក្តាខៀន ទ្វារ បង្អួចជាដើម) និងអនាម័យក្នុង សាលា និងបរិវេណសាលា ដោយមិនចោលសំរាមផ្តេសផ្តាស និងមិនត្រូវខាកស្តោះលើឥដ្ឋ។
- មាតាបិតាត្រូវទទួលចេញសំណងខូចខាតដល់សាលាក្នុងករណីសិស្ស គូសវាស ឬបំផ្លិច បំផ្លាញ ទ្រព្យសម្បត្តិរបស់សាលា។
- មិនត្រូវញ៉ាំចំណីអាហារក្នុងបន្ទប់រៀន និងហាមញ៉ាំស្ករ (ស្ករគ្រាប់ ឬស្ករកៅស៊ូ) ក្នុងបរិវេណ សាលារៀន។

ចំពោះការមិនអនុវត្តនូវចំណុចខាងលើនឹងត្រូវទទួលពិន័យដូចខាងក្រោម៖

- ➢ ត្រូវទទួលការណែនាំនៅការិយាល័យកិច្ចការសិស្ស និងអនុញ្ញាតឲ្យចូលរៀន។
- ➢ ទទួលការណែនាំពីក្រុមប្រឹក្សាវិន័យ ហើយនឹងត្រូវបានផ្តល់ព័ត៌មានទៅមាតាបិតា ឬ អាណាព្យាបាល។
- ➢ មិនអនុញ្ញាតអោយចូលរៀន និងចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាវិន័យ ហើយសាលា និង អញ្ជើញមាតាបិតា ឬអាណាព្យាបាលដោយគោរពតាមគោលការណ៍ទើបសាលាអនុញ្ញាត អោយចូលរៀនវិញ។
- ➢ ទទួលយកគ្រប់វិធានការរបស់សាលាដោយឥតលក្ខខណ្ឌ។

**ឃ.កិច្ចការផ្ទះ**

- យកកិច្ចការផ្ទះទៅអោយមាតាបិតា ឬអាណាព្យាបាលពិនិត្យ និងចុះហត្ថលេខាទទួល ស្គាល់។
- មិនត្រូវលួចចម្លង ឬយកកិច្ចការផ្ទះអ្នកដទៃមកធ្វើកម្មសិទ្ធិរបស់ខ្លួនឡើយ។
- ក្នុងករណីអនុវត្តខុសការចែងខាងលើនឹងទទួលបានពិន្ទុសូន្យ និងការពិន័យដូចខាងក្រោម

- ✓ ទទួលការណែនាំផ្ទាល់ពីលោកគ្រូ អ្នកគ្រូ។
- ✓ ផ្តល់ព័ត៌មានជូនមាតាបិតា ឬអាណាព្យាបាល និងសិស្សត្រូវចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាវិន័យ។
- ✓ អញ្ជើញមាតាបិតា ឬអាណាព្យាបាលសិស្សមកពិភាក្សា និងចុះកិច្ចសន្យាជាមួយសាលា។
- ✓ ទទួលយកគ្រប់វិធានការរបស់សាលាដោយឥតលក្ខខណ្ឌ។

**ខ.អវត្តមាន និងបទវិន័យ**

- សាលានឹងផ្តល់ព័ត៌មានទៅដល់មាតាបិតា និងអាណាព្យាបាលក្នុងករណីសិស្សអវត្តមានឥតច្បាប់។
- ការដាក់អវត្តមានត្រូវបានកំណត់ដូចខាងក្រោមៈ
  - ➢ មកយឺតចាប់ពី ១៥ នាទីចំនន្ទួន ៣ ដង គិតអវត្តមានអត់ច្បាប់មួយដង និងមកយឺតចាប់ពី ៣០ នាទីចំនួនមួយដង គិតអវត្តមានឥតច្បាប់មួយដង។
  - ➢ ឈប់ ១ ម៉ោង ១ ព្រឹក ឬ ១ រសៀល ក៏គិតស្មើនឹងឈប់មួយដងដូចគ្នា។
  - ➢ អវត្តមានអត់ច្បាប់ចំនួន ៨ ដងសាមីខ្លួននឹងត្រូវធ្វើការណែនាំ និងចុះកិច្ចសន្យាព្រមទាំង ជូនព័ត៌មានដល់មាតាបិតា ឬអាណាព្យាបាល។
  - ➢ អវត្តមានអត់ច្បាប់ចំនួន ១៥ ដងសាមីខ្លួននឹងត្រូវព្រមាន និងចុះកិច្ចសន្យាជាលើកចុងក្រោយ ហើយអញ្ជើញមាតាបិតា ឬអាណាព្យាបាលមកទទួលព័ត៌មាន។
  - ➢ អវត្តមានអត់ច្បាប់ចាប់ពី ២១ ដងឡើងទៅ ទោះបីជាជាប់មធ្យមភាគពិន្ទុក៏ត្រូវរៀនត្រួតថ្នាក់។
  - ➢ អវត្តមានមានច្បាប់ចាប់ពី ៨៦ ដងឡើងទៅនឹងត្រូវលុបឈ្មោះចេញពីបញ្ជីរបស់សាលា។
  - ➢ អវត្តមានមានច្បាប់ និងអត់ច្បាប់ចាប់ពី ៣១ ដងឡើងទៅ ទោះបីជាប់ពិន្ទុមធ្យមភាគក៏ត្រូវរៀនត្រួតថ្នាក់។
  - ➢ អវត្តមានមានច្បាប់ចាប់ពី ៣០ ដងទៅ ៨៥ ដង
- ចំពោះសិស្សជាប់មធ្យមភាគពិន្ទុប្រចាំឆ្នាំនឹងត្រូវបានឡើងថ្នាក់
- ចំពោះសិស្សធ្លាក់មធ្យមភាគពិន្ទុប្រចាំឆ្នាំនឹងត្រូវរៀនត្រួតថ្នាក់

**គ.ការសុំអនុញ្ញាតច្បាប់**

- សិស្សសុំលិខិតអនុញ្ញាតច្បាប់នៅការិយាល័យសិក្សា ដោយបំពេញបែបបទដោយមានហត្ថលេខាពីមាតាបិតា ឬអាណាព្យាបាល និងប្រគល់ជូនវិញយ៉ាងហោចណាស់មួយថ្ងៃមុនថ្ងៃឈប់។
- ករណីបន្ទាន់សិស្សអាចស្នើឲ្យមាតាបិតា ឬអាណាព្យាបាលទាក់ទងមកសាលាតាមទូរស័ព្ទ ដើម្បី សុំអនុញ្ញាតច្បាប់ ហើយពេលត្រឡប់មកវិញសិស្សត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីមូលហេតុ ដោយមានចុះហត្ថលេខាមាតាបិតា ឬអាណាព្យាបាលមកប្រគល់ជូនការិយាល័យសិក្សា ឬកិច្ចការសិក្សាយ៉ាងហោចរយៈពេល ២ ថ្ងៃ ដើម្បីបញ្ជាក់ថាអវត្តមាននោះមានច្បាប់ ហើយសាលានឹងទាក់ទងទៅមាតាបិតា ឬអាណាព្យាបាលដើម្បីបញ្ជាក់ពីការឈប់នោះ។

**ឆ.ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា**

- ហាមប្រើប្រាស់ទូរស័ព្ទដៃ ឬប្រអប់ល្បែងលេងផ្សេងៗ ក្នុងម៉ោងរៀន បើមានករណីនោះសាលានឹងដកហូតមករក្សាទុក ដោយមិនអនុញ្ញាតអោយដកចេញនូវផ្នែកណាមួយឡើយ ដូចជា ស៊ីម អង្គចងចាំជាដើម និងមានវិធានការដូចជា៖
  - ➢ រក្សាទុករយៈពេល ១ សប្តាហ៍
  - ➢ រក្សាទុករយៈពេល ២ សប្តាហ៍
  - ➢ រក្សាទុករយៈពេល ១ ខែ
  - ➢ រក្សាទុករយៈពេល ៦ ខែ
  - ➢ រក្សាទុករយៈពេល ១ ឆ្នាំ
  - ➢ បញ្ឈប់សិស្សពីការសិក្សាដោយឥតលក្ខខណ្ឌ។
- ហាមមើលរូបភាព ឬវីដេអូអាសអាភាសក្នុងឧបករណ៍បច្ចេកវិទ្យាផ្សេងៗ ក្នុងបរិវេណសាលា បើមានករណីនោះសាលានឹងដកហូតមករក្សាទុក ដោយមិនអនុញ្ញាតអោយដកចេញនូវផ្នែកណាមួយឡើយ និងមានវិធានការដូចជា៖
  - ✓ រក្សាទុករយៈពេល ១ ខែ ហើយអញ្ជើញមាតាបិតា ឬអាណាព្យាបាលមកចុះកិច្ចសន្យា
  - ✓ រក្សាទុករយៈពេល ២ ខែ ហើយអញ្ជើញមាតាបិតា ឬអាណាព្យាបាលមកចុះកិច្ចសន្យា
  - ✓ បញ្ឈប់សិស្សពីការសិក្សាដោយឥតលក្ខខណ្ឌ (មើលឧបសម្ព័ន្ធទី៨ បន្ថែម)

### ៣.១.៦ អាហារូបករណ៍(រង្វាន់សិស្សពូកែ)

ដើម្បីជម្រុញឱ្យសិស្ស ខិតខំព្យាយាមសិក្សារៀនសូត្រកាន់តែប្រសើរឡើងថែមទៀត សាលារៀនសុវណ្ណភូមិបានរៀបចំឱ្យមានការលើកទឹកចិត្តដល់សិស្សតាមរយៈ ការផ្តល់ជាអាហារូបករណ៍និង មានជារង្វាន់ផ្សេងៗទៀតដូចជា ៖

- បិទរូបថតនៅលើតារាងកិត្តិយសក្នុងថ្នាក់
- ផ្សាយតាមព្រឹត្តិប័ត្រប្រចាំឆ្នាំរបស់សាលា
- ចេញលិខិត ឬបណ្ណសរសើរដល់សិស្សឆ្នើម
- ផ្តល់ជាអាហារូបករណ៍ និងជូនជារង្វាន់។

❖ លក្ខខណ្ឌក្នុងការទទួលបានរង្វាន់

**ក.សិស្សពូកែក្នុងថ្នាក់**

- សិស្សដែលអាចចាត់ទុកថា ជាសិស្សប្រចាំឆមាសបានលុះត្រាតែជាសិស្សជាប់ចំណាត់ថ្នាក់មធ្យភាគប្រចាំឆមាស កម្រិតពិន្ទុខ្ពស់ជាងគេ និង បន្តបន្ទាប់ ហើយពិន្ទុមធ្យមភាគគិតចាប់ពី៧០%ឡើង ទៅនៃពិន្ទុមធ្យមភាគប្រចាំឆមាសសរុប។
- សិស្សដែលអាចចាត់ទុកថាជាសិស្សពូកែប្រចាំឆ្នាំបាន លុះត្រាតែជាសិស្សជាប់ចំណាត់ថ្នាក់មធ្យមភាគប្រចាំឆ្នាំកម្រិតពិន្ទុខ្ពស់ជាងគេ និង បន្តបន្ទាប់ហើយពិន្ទុមធ្យមភាគគិតចាប់ពី ៧០% ឡើងនៃពិន្ទុមធ្យមភាគប្រចាំឆ្នាំសរុប។
- ចំណាត់ថ្នាក់ដែលកំណត់ថា ត្រូវទទួលរង្វាន់គឺ៖
    - ចំពោះថ្នាក់ដែលមានសិស្សចាប់ពី ០១នាក់ ដល់ ១០នាក់ កំណត់យកត្រឹមចំណាត់ថ្នាក់លេខ១
    - ចំពោះថ្នាក់ដែលមានសិស្សចាប់ពី ១១នាក់ ដល់ ២០នាក់ កំណត់យកត្រឹមចំណាត់ថ្នាក់លេខ៣
    - ចំពោះថ្នាក់ដែលមានសិស្សចាប់ពី២១ នាក់ឡើងទៅ កំណត់យកត្រឹមចំណាត់ថ្នាក់លេខ៥
- រង្វាន់ផ្តល់ជូន៣លើក្នុងមួយឆ្នាំ (ប្រចាំឆមាសទី១ ឆមាសទី២ និង ប្រចាំឆ្នាំ)។

**ខ. សិស្សប្រឡងប្រជែងខាងក្រៅ**

សិស្សដែលប្រឡងប្រជែងខាងក្រៅ គឺជាសិស្សដែលបានចូលរួមប្រឡងប្រជែងជាមួយនឹងស្ថាប័នដទៃទៀត។ សិស្សជាប់ចំណាត់ថ្នាក់នឹងទទួលបានរង្វាន់តាមកម្មវិធីប្រឡងជាក់ស្តែង។

ក្រៅពីរង្វាន់ទទួលបានពីកម្មវិធីប្រឡងប្រជែង សាលាមានរៀបចំរង្វាន់លើកទឹកចិត្តដោយឡែកទៀតដូចជា ផ្តល់ជាអាហារូបករណ៍ បណ្ណសរសើរ និង កាដូអនុស្សាវរីយ៍ផ្សេងៗទៀតជាដើម។

❖ កម្រិតនៃអាហារូបករណ៍

- ចំណាត់ថ្នាក់ទី១ ទទួលបានអាហារូបករណ៍ ៥០%
- ចំណាត់ថ្នាក់ទី២ ទទួលបានអាហារូបករណ៍ ៤០%
- ចំណាត់ថ្នាក់ទី៣ ទទួលបានអាហារូបករណ៍ ៣០%
- ចំណាត់ថ្នាក់ទី៤ ទទួលបានអាហារូបករណ៍ ២០%
- ចំណាត់ថ្នាក់ទី៥ ទទួលបានអាហារូបករណ៍ ១០%

អាហារូបករណ៍ទាំងនេះ គឺមានរយៈពេលមួយឆ្នាំសិក្សា។ នេះបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់សាលារៀន សុវណ្ណភូមិ បឹងត្របែក ទៅលើការសិក្សារបស់សិស្ស ព្រមទាំងមានការផ្តល់នូវរង្វាន់លើកទឹកចិត្តដល់ការខិតខំប្រឹងប្រែងរបស់សិស្សទៀតផងដែរ។

### ៣.១.៧ ការប្រកួតប្រជែងផ្សេងៗ

ក្រៅពីសកម្មភាពអប់រំនៅក្នុងថ្នាក់ និង ក្រៅថ្នាក់ហើយសាលារៀនសុវណ្ណភូមិក៏បានបង្កើតនូវ ការប្រឡងប្រជែងផ្សេងៗទៀតសម្រាប់សិស្សបឋមសិក្សាដើម្បីជ្រើសរើសយកសិស្សដែលមានសមត្ថភាពពិតប្រាកដទៅតាម ផ្នែកនិងជំនាញនីមួយៗរបស់ពួកគេ។ ការប្រកួតប្រជែងនេះផងដែរចាប់ផ្តើមធ្វើឡើងដោយមានការប្រឡងប្រណាំងនៅតាមបណ្តាលសាខានីមួយៗសិន គឺដើម្បីធ្វើការជ្រើសរើសសិស្សយកទៅប្រឡងប្រជែង បន្តជាមួយនឹងសាខាផ្សេងៗទៀតនៃក្រុបខណ្ឌ អ៊ិន ធី ស៊ី គ្រុប រួចជ្រើសរើសយកសិស្សពូកែក្នុង សាលារៀន សុវណ្ណភូមិទាំងអស់ទូទាំងប្រទេស។

ការប្រកួតប្រជែងទាំងនោះមានដូចជាៈ

- **កម្មវិធីប្រឡងអក្ខរវិញ្ញាស(សម្រាប់ថ្នាក់ទី៤-៦)** ៖ ធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យសិស្សចេះ សរសេរ និង អានពាក្យខ្មែរ ព្រមទាំងយល់នូវន័យសេចក្តីរបស់ពាក្យទាំងនោះឱ្យបានច្បាស់លាស់។ មិនតែប៉ុណ្ណោះក៏ធ្វើឱ្យសិស្សនៅកម្រិតបឋមសិក្សាបានស្វែងយល់កាន់តែច្បាស់ពីស្វរនៃស្រៈ ព្យញ្ជនៈ និង សញ្ញាវណ្ណយុតទាំងអស់ដែលមាននៅក្នុងភាសាខ្មែរយើង។ ជាងនេះទៅទៀត កម្មវិធីនេះក៏ជាផ្នែកមួយនៃការជួយលើកស្ទួយវិស័យអក្សរសាស្ត្រខ្មែរយើង ឱ្យមានការរីកចំរើនកាន់តែខ្លាំងឡើងតាមរយៈការខិតខំសិក្សា ស្រាវជ្រាវបន្ថែមរបស់បេក្ខជននីមួយៗ។

- **កម្មវិធីប្រកួតប្រជែងការបង្កើតឧបករណ៍វិទ្យាសាស្ត្រ(STEM)៖** គឺជាការប្រឡងប្រជែងមួយ ដើម្បីឱ្យសិស្សប្រើការច្នៃប្រឌិតរបស់ខ្លួនមកបង្កើតជាឧបករណ៍ផ្សេងៗដែលទាក់ទង ជាមួយនឹងវិទ្យាសាស្ត្រ ព្រមទាំងបានបណ្តុះនូវបំណិននិយាយផ្អែកលើគំនិតច្នៃប្រឌិត របស់សិស្សា នុសិស្សផងដែរ។ ជាងនេះទៅទៀត កម្មវិធីមួយនេះក៏ជាផ្នែកនៃការអប់រំ សិស្សឱ្យចូលចិត្តធ្វើការស្រាវជ្រាវពីអ្វីដែលថ្មីៗ និងយកមកបង្កើតជាឧបករណ៍ដែលមាន អត្ថប្រយោជន៍ទៅថ្ងៃខាងមុខ និងជាគ្រឹះសម្រាប់ប្អូនៗសិស្សានុសិស្សណាដែលមាន បំណងប្រាថ្នាចង់ក្លាយជាអ្នកវិទ្យាសាស្ត្រទៅថ្ងៃអនាគត។
- **កម្មវិធីប្រកួតកីឡា៖** រៀបចំឡើងជារៀងរាល់ឆ្នាំសិក្សា ដើម្បីផ្តល់ឱកាសបង្ហាញសមត្ថភាព ដល់សិស្សដែលចូលចិត្តវិស័យកីឡា។ ម៉្យាងវិញទៀត កីឡាក៏នាំមកនូវសុខភាព មិត្តភាព សាមគ្គីភាព និង វិន័យផងដែរ។
- **កម្មវិធីប្រកួតរបាំ៖** នៅក្នុងកម្រិតបឋមសិក្សា(ថ្នាក់ទី១-៦) ក៏បានបង្កើតនូវការប្រឡងរាំរបាំ ជារៀងរាល់ឆ្នាំផងដែរ។ កម្មវិធីនេះ ធ្វើឡើងក្នុងគោលបំណងឱ្យក្មេងជំនាន់ក្រោយស្គាល់ពី ទំនៀមទម្លាប់ប្រពៃណី វប្បធម៌របស់ខ្មែរ និងប្រកាន់ខ្ជាប់ដើម្បីថែរក្សាវប្បធម៌របស់ខ្លួនឱ្យ បានគង់វង្ស។

កម្មវិធីប្រឡងប្រជែងទាំងអស់ខាងលើនេះ ក៏បានបណ្តុះនូវភាពក្លាហាន ភាពវៃឆ្លាត ការប៉ិន ប្រសប់ក្នុងការនិយាយបកស្រាយជាសាធារណៈ និង ភាពមានជំនឿទុកចិត្តដល់កុមារ ដែលជា គ្រឹះមួយដ៏ល្អសម្រាប់ឱ្យពួកគេបន្តទៅថ្នាក់មធ្យមសិក្សាផងដែរ។ (មើលឧបសម្ព័ន្ធទី៩)

### ៣.១.៨ សេវាកម្មបន្ថែម

ក្រៅពីបម្រើសេវាកម្មបង្រៀន និង អប់រំ សាលារៀន សុវណ្ណភូមិ បឹងត្របែកក៏មាននូវសេវា កម្មមួយចំនួនទៀតដែលជួយសម្រួលដល់អាណាព្យាបាល ឬ មាតាបិតាសិស្សណាដែលជាប់រវល់ ច្រើន។ សេវាកម្មទាំងនោះមានដូចជា៖

- **សេវាកម្មដឹកជញ្ជូនសិស្ស៖** សិស្សទាំងអស់អាចមកសាលាតាមរយៈ រថយន្តរបស់សាលា ឬតាមមធ្យោបាយផ្ទាល់ខ្លួន។ រថយន្តរបស់សាលាមានបម្រើសេវាកម្មជាច្រើននៅក្នុងរាជ ធានីភ្នំពេញ និងតាមបណ្តាលខេត្តដែលមានសាលារៀនសុវណ្ណភូមិ។ សម្រាប់បទបញ្ញត្តិ នៅក្នុងការដឹកជញ្ជូនមានដូចតទៅៈ សាលារៀនសុវណ្ណភូមិ សាខាបឹងត្របែកមានសេវា កម្មដឹកជញ្ជូនដោយប្រើរថយន្ត ខ្នាតកណ្តាលចំណុះ ១២ កៅអី និង ១៥ កៅអី សម្រាប់ ជួយសម្រួលដល់ការធ្វើដំណើរមកកាន់សាលា ឬ ចេញពីសាលា។ ដោយសារតែការពិនិ ត្យឃើញមានគ្រោះថ្នាក់ចរាចរណ៍ច្រើននៅតាមដងផ្លូវ អ្នកបើកបរត្រូវផ្តោតអារម្មណ៍

ទាំងស្រុងទៅលើការបើកបរ ដោយមិនត្រូវមានការរំខានពីសិស្ស ដែលជិះនៅក្នុងរថយន្ត នោះឡើយ។ ដូចនេះសិស្សទាំងអស់ត្រូវប្រកាន់ឥរិយាបថដូចជា៖

- សិស្សនៅក្នុង រថយន្តមិនត្រូវមានការបរិភោគអាហារ ឬ ភេសជ្ជៈ
- មិនត្រូវមានសំឡេងជជែកឡូឡា ឬភ្លេងតន្ត្រី ឬការដើរកត់ចុះឡើងក្នុងរថយន្ត...។
- សិស្សគ្រប់រូបដែលមិនបានចុះឈ្មោះជិះរថយន្ត មិនអាចជិះរថយន្តបានឡើយ។
- សិស្សដែលឆាផៅរំខាន នៅក្នុងរថយន្ត នឹងត្រូវរាយការណ៍ទៅគណៈគ្រប់គ្រងសាលា ដើម្បីធ្វើការទំនាក់ទំនងទៅមាតាបិតា ឬ អាណាព្យាបាលសិស្សនោះ។
- ចំពោះសិស្សដែលមិនរាងចាល ហើយនៅតែបន្តប្រព្រឹត្តិកំហុស នឹងត្រូវហាមឃាត់មិនឱ្យជិះរថយន្តចំនួន ៥ ថ្ងៃ បន្ទាប់ពីការព្រមានជាលើកទី២។
- ប្រសិនបើមានការព្រមានជាលើកទី ៣ ហើយសិស្សនោះនឹងត្រូវបានផ្អាកមិនឱ្យជិះ រថយន្ត។ មួយវិញទៀតផងដែរ ចំពោះទឹកប្រាក់ដែលបាននៅសល់សាលាពុំមានការទូទាត់សងទៅវិញឡើយ។

- **សេវាកម្មស្នាក់នៅក្នុងសាលា៖** ដើម្បីជួយសម្រួលដល់ការសិក្សារបស់ប្អូនៗសិស្សានុសិស្សដែលរៀនពីរវេន ជាពិសេសកុមារតូចៗ សាលារៀនសុវណ្ណភូមិ បឹងត្របែក បានរៀបចំឱ្យមានកន្លែងស្នាក់នៅ និងទទួលអាហារសម្រាប់ថ្ងៃត្រង់របស់ប្អូនៗ។ សិស្សានុសិស្សដែលស្នាក់នៅក្នុងសាលាទាំងអស់ ត្រូវគោរពតាមគោលការណ៍ណែនាំ ឬ បទបញ្ជាផ្ទៃក្នុងសម្រាប់អ្នកស្នាក់នៅដូចខាងក្រោម៖

  - រក្សាភាពស្ងៀមស្ងាត់ មិនស្រែកឡូឡា រំខានអ្នកដទៃ
  - ត្រូវមានអនាម័យ និងមានសណ្តាប់ធ្នាប់ក្នុងការហូបចុក និង ស្នាក់នៅ
  - មិនបង្កជម្លោះជាមួយមិត្តភក្តិដទៃ
  - មិនត្រូវគូសវាសផ្តេសផ្តាស បិទរូបភាពលើជញ្ជាំង
  - ជួយថែរក្សាទ្រព្យសម្បត្តិសាលារៀន
  - មិនត្រូវធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិសាលា
  - មិនត្រូវយករបស់មានតម្លៃ (គ្រឿងអលង្ការ ទូរស័ព្ទ...) ចូលកន្លែងស្នាក់នៅ ព្រោះសាលាមិនទទួលខុសត្រូវរាល់ការបាត់បង់ឡើយ។

សិស្សដែលមិនគោរពតាមគោលការណ៍ បង្កជាបញ្ហានឹងត្រូវរាយការណ៍ទៅគណៈគ្រប់គ្រងសាលា ដើម្បីធ្វើការទំនាក់ទំនងទៅមាតាបិតា ឬអាណាព្យាបាលសិស្សនោះ។ ចំពោះសិស្សដែលមិនរាងចាល ហើយនៅតែបន្តប្រព្រឹត្តិកំហុសនឹងត្រូវហាមឃាត់ មិនឱ្យស្នាក់នៅរយៈ

ពេល ៥ ថ្ងៃ បន្ទាប់ពីការព្រមានលើកទី២។ ប្រសិនបើមានការព្រមានលើកទី ៣ សិស្សនោះនឹងត្រូវផ្អាក មិនឱ្យស្នាក់នៅក្នុងសាលាទៀតទេ។ មួយវិញទៀតចំពោះទឹកប្រាក់ ដែលនៅសល់សាលាពុំមានការទូទាត់សងឡើយ។

## ៣.២ ផ្នែករដ្ឋបាល

ការងាររដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងសកម្មភាពអប់រំរបស់សាលារៀនសុវណ្ណភូមិ បឹងត្របែក។

### ៣.២.១ នីតិវិធីក្នុងការជ្រើសរើសគ្រូបង្រៀនចំណេះទូទៅខ្មែរ

ដើម្បីលើកកម្ពស់គុណភាពអប់រំ និងដើម្បីឱ្យការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធិភាពខ្ពស់ កត្តាគ្រូបង្រៀនគឺជារឿងសំខាន់ និងចាំបាច់បំផុតដែលត្រូវយកចិត្តទុកដាក់។ ដើម្បីទទួលបានគ្រូល្អ ចាំបាច់ត្រូវមាននីតិវិធីជ្រើសរើសដូចខាងក្រោម៖

- ផ្សព្វផ្សាយព័ត៌មាន ស្ដីពីការជ្រើសរើស
  - កំណត់តំណែងដែលត្រូវជ្រើសរើស
  - កំណត់លក្ខខណ្ឌទាក់ទងតំណែង
  - កម្រិតសញ្ញាបត្រសមស្របនឹងតំណែង
  - កំណត់កាលបរិច្ឆេទទទួល និងបញ្ឈប់នៃការទទួលពាក្យ
- សម្រិតសម្រាំងបេក្ខជន
  - ពិនិត្យលើសំណុំឯកសារគ្រូ ស្របតាមលក្ខខណ្ឌខាងលើ
  - ជ្រើសរើសបេក្ខជនដែលមានលក្ខខណ្ឌសមស្របនឹងតំណែង
  - រៀបចំបញ្ជីឈ្មោះបេក្ខជនបិទផ្សាយ
- ដំណើរការធ្វើតេស្ត សម្ភាន៍ និងបង្រៀនសាកល្បង
  - ធ្វើតេស្តសរសេរទាក់ទងចំណេះដឹង ជំនាញនិង គរុកោសល្យ ពិន្ទុខ្ពស់បំផុតគឺ៥
  - ធ្វើសម្ភាសន៍ផ្ទាល់មាត់ ពិន្ទុខ្ពស់បំផុតគឺ ៥
  - រៀបចំកិច្ចតែងការបង្រៀន និង បង្រៀនសាកល្បងពិន្ទុខ្ពស់បំផុតគឺ ៥
- ការសម្រេចជ្រើសរើស
  - បេក្ខជនដែលជាប់ក្នុងការជ្រើសរើស លុះត្រាតែមធ្យមភាគ( ពិន្ទុតេស្តសរសេរ ពិន្ទុសម្ភាសន៍ និង ពិន្ទុបង្រៀនសាកល្បង) ខ្ពស់ជាងគេក្នុងចំណោមបេក្ខជនចូលរួមទាំងអស់ ហើយពិន្ទុមធ្យមភាគត្រូវកំណត់ចាប់ពី ៣៥ ឬ៧០% ឡើងទៅ។

- ○ បេក្ខជនដែលជាប់ត្រូវសាកល្បងការងាររយៈពេល ៣ ខែ
- ○ បីខែក្រោយប្រសិនបើពិនិត្យឃើញថា បេក្ខជនមានលក្ខណៈគ្រប់គ្រាន់ សាលានឹងត្រូវបញ្ចូលជាគ្រូពេញសិទ្ធិ
- ○ ក្នុងករណីលក្ខណៈសម្បត្តិរបស់បេក្ខជន មិនអាចទទួលយកបាន នោះសាលានឹងបញ្ចប់កិច្ចសន្យាខ្លី និងមិនបន្តកិច្ចសន្យាទៀតទេ។

**៣.២.២ ប្រព័ន្ធវាយតម្លៃលើការបង្រៀនរបស់គ្រូ**

គ្រូបង្រៀនចំណោះទូទៅខ្មែរកម្រិតបឋមសិក្សា ត្រូវបានវាយតម្លៃលើការបង្រៀនជារៀងរាល់ឆ្នាំ។ គោលបំណងនៃការវាយតម្លៃនេះ គឺដើម្បីធ្វើយ៉ាងណាឱ្យការអប់រំមួយទទួលបានប្រសិទ្ធភាព និង គុណភាពខ្ពស់។ ក្នុងការវាយតម្លៃនេះ ក៏ផ្តល់នូវអត្ថប្រយោជន៍ផងដែរចំពោះគ្រូបង្រៀន ព្រោះថាលទ្ធផលនៃការវាយតម្លៃ ជាស្តង់ដាសម្រាប់បន្ថែមនូវប្រាក់បៀវត្សប្រចាំឆ្នាំនីមួយៗ។ លក្ខខណ្ឌនៃការថែមនេះ មានចែងនៅក្នុងស្តង់ដាប្រាក់បៀវត្សផងដែរ។ ការវាយតម្លៃទៅលើគ្រូដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

- ការវាយតម្លៃដោយសិស្សៈ ការវាយតម្លៃគ្រូពីសិស្ស ធ្វើឡើងក្នុងមួយឆ្នាំ ២ដង គឺនៅចុងឆមាសទី១ និង ចុងឆមាសទី២។ ការវាយតម្លៃនេះ ដោយយោងទៅតាមកម្រងសំណួរដែលរៀបចំរួចជាស្រេច។ លទ្ធផលនៃការវាយតម្លៃនេះ គិតប្រចាំឆ្នាំដោយយកលទ្ធផលឆមាសទី១ បូកនឹងលទ្ធផលឆមាសទី ២ គិតជាមធ្យមពិន្ទុសរុប៥០%។
- ការវាយតម្លៃពីគណៈគ្រប់គ្រងសាលាៈ ការវាយតម្លៃគ្រូពីថ្នាក់ដឹកនាំសាលារៀន ដោយធ្វើឡើងក្នុងមួយឆ្នាំម្តង ទៅតាមកម្រងសំណួរដែលបានរៀបរួចជាស្រេច។ ពិន្ទុនៃការវាយតម្លៃ នេះគឺសរុប ៥០%។

សរុបជារួម លទ្ធផលនៃការវាយតម្លៃគ្រូបង្រៀន គឺត្រូវយកពិន្ទុវាយតម្លៃពីសិស្ស (៥០%) បូកជាមួយពិន្ទុដែលបានវាយតម្លៃពីថ្នាក់ដឹកនា( ៥០%) ចេញជាពិន្ទុវាយតម្លៃគ្រូប្រចាំឆ្នាំ។

**៣.២.៣ ការចុះអធិការកិច្ចរបស់មន្ទីរអប់រំ យុវជន និង កីឡា**

មន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញ បានចុះអធិការកិច្ចសាលារៀន សុវណ្ណភូមិ សាខា បឹងត្របែក ជារៀងរាល់ឆ្នាំសិក្សាទៅលើការគ្រប់គ្រងរដ្ឋបាល បរិស្ថាន ការបង្រៀន និង សម្ភារឧបទេស ដូចទៅនឹងសាលាចំណោះទូទៅ ឯកជនផ្សេងៗដែរ។ ការធ្វើអធិការកិច្ចនេះ មិនធ្វើឡើងតាមលំដាប់លំដោយនៃការរៀបរាប់ខាងលើទេ គឺអាស្រ័យទៅលើសំណូមពររបស់មន្ត្រីអធិការកិច្ច។ ដូច្នេះហើយសាលាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងមន្ត្រី

អធិការកិច្ច។ មិនតែប៉ុណ្ណោះ សាលាបានទទួលអនុសាសន៍ល្អៗជាច្រើនដើម្បីបំពេញភាពខ្វះខាត និង បន្តចំណុចវិជ្ជមានរបស់ខ្លួន ក្នុងគោលដៅធានាបាននូវការផ្តល់សេវាអប់រំដែលមានគុណភាព ទៅដល់សិស្ស។

### ៣.៣ សមិទ្ធផលសម្រេចបានកន្លងមករបស់សាលារៀន សុវណ្ណភូមិ បឹងត្របែក

សាលារៀន សុវណ្ណភូមិ បឹងត្របែកកន្លងមកបានសម្រេចសមិទ្ធផលជាច្រើនក្នុង សកម្មភាពអប់រំ យុវជន និង កីឡាដូចជា៖

- សិស្សបានជាប់ជាស្ពាពរ ១០០% នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅឆ្នាំសិក្សា ២០១៧-២០១៨។
- សិស្សបានជាប់ និទ្ទេស A ១នាក់ នៃការប្រឡងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ នៅឆ្នាំសិក្សា ២០១៧-២០១៨ ។(មើលឧបសម្ព័ន្ធទី១០)
- ទទួលបានលទ្ធផលលេខ ២ ក្នុងការប្រឡងប្រកួតប្រជែងការបង្កើតឧបករណ៍វិទ្យាសាស្រ្ត (STEM) ក្នុងក្របខណ្ឌ អ៊ិន ធី ស៊ី គ្រុប កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៩។
- ទទួលបានលទ្ធផល លេខ១ ក្នុងការប្រឡងអក្ខរវិញ្ញាសថ្នាក់បឋមសិក្សា ក្នុងក្របខណ្ឌ អ៊ិន ធី ស៊ី គ្រុប នៅឆ្នាំ សិក្សា ២០១៧-២០១៨

### ៣.៤ ទស្សនៈវិស័យពេលអនាគត

- ដាក់ Slide ឱ្យមានប្រើប្រាស់គ្រប់បន្ទប់ដើម្បីជាជំនួយដល់ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ
- ធ្វើយ៉ាងណាឱ្យបរិមាណសិស្សមានការកើនឡើងជាបន្តបន្ទាប់

# ជំពូកទី៤៖ ការវិភាគទៅលើទិន្នន័យសិស្សពីខែមករា ដល់ ខែមីនាក្នុងឆ្នាំ ២០១៩

## ៤.១ ទិន្នន័យ និងការវិភាគចំនួនសិស្សបឋមសិក្សាជាភាសាជាតិ ពីខែមករា ដល់ខែមីនា ក្នុងឆ្នាំ២០១៩

ចាប់ពីខែមករា ដល់ខែមីនា ក្នុងឆ្នាំ២០១៩ យើងទទួលបាននូវទិន្នន័យចំនួនសិស្សថ្នាក់បឋមសិក្សា(ថ្នាក់ទី១ ដល់ថ្នាក់ទី៦)នៅក្នុងសាលារៀនសុវណ្ណភូមិ សាខាបឹងត្របែក។ [១៣]

### ៤.១.១ តារាងចំនួនសិស្សសរុបទាំង៣ខែតាមថ្នាក់នីមួយៗ

ទិន្នន័យចំនួនសិស្សសរុបតាមថ្នាក់នីមួយៗគិតជានាក់៖

| ខែ / កម្រិតថ្នាក់ | មករា | កុម្ភៈ | មីនា |
|---|---|---|---|
| ថ្នាក់ទី១ | ៣០ | ៣៥ | ៤០ |
| ថ្នាក់ទី២ | ២៧ | ៣០ | ៣៧ |
| ថ្នាក់ទី៣ | ៣៦ | ៣៨ | ៤៥ |
| ថ្នាក់ទី៤ | ៣០ | ៣២ | ៣៨ |
| ថ្នាក់ទី៥ | ៣៣ | ៣២ | ៣៧ |
| ថ្នាក់ទី៦ | ២៧ | ៣០ | ៣៥ |
| **សរុបចំនួនសិស្ស** | ១៨៣នាក់ | ១៩៧នាក់ | ២៣២នាក់ |

[១៣] សម្ភាសដោយផ្ទាល់ពីលោក ម៉ុម ហាញ ដែលមានតួនាទីជាអ្នកសម្របសម្រួលថ្នាក់ចំណេះទូទៅខ្មែរនៃសាលារៀនសុវណ្ណភូមិ បឹងត្របែក

### ៤.១.២ ការវិភាគចំនួនសិស្សសរុបតាមក្រាហ្វិក




ការវិភាគតាមក្រាហ្វិកខាងលើ បង្ហាញឱ្យយើងឃើញថា ចំនួនសិស្សសរុបតាមថ្នាក់នីមួយៗនៅក្នុងកម្រិតបឋមសិក្សារបស់សាលារៀនសុវណ្ណភូមិ សាខាបឹងត្របែក ពីខែមករា ដល់ខែមីនា ក្នុងឆ្នាំ២០១៩ មានស្ថានភាពដូចខាងក្រោម៖

- ខែមករា (ឆ្នាំ២០១៩)៖ ចំនួនសិស្សសរុបពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៅក្នុងសាលារៀនសុវណ្ណ-ភូមិ សាខាបឹងត្របែក មានចំនួន ១៨៣ នាក់។
- សម្រាប់ខែកុម្ភៈ (ឆ្នាំ២០១៩)៖ ចំនួនសិស្សសរុបពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៅក្នុងសាលារៀនសុវណ្ណភូមិ សាខាបឹងត្របែក មានចំនួន ១៩៧ នាក់ ហើយបើយើងធ្វើការប្រៀបធៀបជាមួយទិន្នន័យសិស្សនៅក្នុងសាលារៀនសុវណ្ណភូមិ កាលពីខែមករាដែលមានចំនួន ១៨៣នាក់។ ដូច្នេះហើយ យើងសង្កេតឃើញថាចំនួនសិស្សានុសិស្ស ដែលរៀនផ្នែកបឋមសិក្សា (ថ្នាក់ទី១ ដល់ទី៦) នៅក្នុងសាលារៀនសុវណ្ណភូមិ សាខាបឹងត្របែក មានការកើនឡើង។ ហើយចំនួនសិស្សដែលបានកើនឡើង នៅក្នុងសាលានេះបើប្រៀបធៀបពីខែចាស់មានចំនួន ១៤ នាក់ ។ ការកើនឡើងនេះគឺមកពីប្រព័ន្ធអប់រំនៅក្នុងសាលារៀននេះមានគុណភាព ស្របតាមស្តង់ដាជាតិ បូកផ្សំជាមួយនឹងការយកចិត្តទុកដាក់ពីសំណាក់គ្រូបង្រៀន ក៏ដូចជាគណៈគ្រប់គ្រងសាលារៀន និង បុគ្គលិកគ្រប់ផ្នែកផ្សេងៗទៀត។

- ក្នុងខែមីនា (ឆ្នាំ២០១៩)៖ ចំនួនសិស្សសរុបពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៅក្នុងសាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក មានចំនួន ២៣២ នាក់ ហើយបើប្រៀបធៀបក្នុងខែកុម្ភៈវិញ ចំនួនសិស្សមាន ១៩៧នាក់។ ដូច្នេះយើងសង្កេតឃើញថា ចំនួនសិស្សកាន់តែកើនឡើង បន្តទៀតឥតឈប់ឈរ គឺកើនឡើងជាងខែមុនចំនួន ៣៥ នាក់។ កំណើននៃចំនួនសិស្ស នេះផងដែរ គឺមកពីកត្តាជាច្រើនដែលមាននៅក្នុងសាលារៀននេះមានដូចជា ការខិតខំព្យាយាមបង្រៀន និង អប់រំពីសំណាក់លោកគ្រូ និង អ្នកគ្រូ ការទំនាក់ទំនងជាមួយនឹង មាតាបិតា ឬអាណាព្យាបាលសិស្សបានជិតស្និទ្ធិ ដែលជាហេតុធ្វើឱ្យគុណភាពរបស់ សាលារៀន កាន់តែមានការផ្សព្វផ្សាយបានទូលាយជាងមុនតាមរយៈអាណាព្យាបាល របស់សិស្ស។

## ៤.២ ការវិភាគ SWOT

ក្រោយពីបានចុះកម្មសិក្សា និងស្វែងយល់ពីសកម្មភាពនៃសាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក រួចមកធ្វើឱ្យក្រុមយើងខ្ញុំសង្កេតឃើញនូវភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងរបស់សាលាដូចខាងក្រោម៖

### ៤.២.១ ភាពខ្លាំង

- គណៈគ្រប់គ្រង ប្រធាន និង ជំនួយការសម្របសម្រួលគ្រប់ផ្នែកនៃសាលារៀន សុវណ្ណភូមិ បឹងត្របែក មានបទពិសោធន៍លើការអប់រំច្រើនឆ្នាំ ដែលពួកគាត់សុទ្ធសឹងតែជាអតីតជាគ្រូបង្រៀន
- សាលារៀន សុវណ្ណភូមិ បឹងត្របែក មានទីតាំងនៅចំកណ្តាលរាជធានីភ្នំពេញ ដែលបង្កភាពងាយស្រួលដល់ការធ្វើដំណើររបស់អាណាព្យាបាល និង សិស្សានុសិស្ស
- សាលារៀនមានដៃគូសហការក្នុងស្រុក និងក្រៅប្រទេសដែលអាចផ្លាស់ប្តូរបទពិសោធន៍ល្អៗពីគ្នាបាន
- សាលាផ្តល់នូវបរិស្ថានសិក្សាល្អ និង មានសុវត្ថិភាពដល់សិស្ស
- កម្មវិធីសិក្សារបស់សាលារៀន សុវណ្ណភូមិ ស្របតាមកម្មវិធីរបស់ក្រសួង អប់រំ យុវជន និងកីឡា
- មានបុគ្គលិកដែលមានភាពស្មោះត្រង់ និងមានការលះបង់ចំពោះសាលា ព្រមទាំងមានលោកគ្រូ អ្នកគ្រូ ដែលមានគរុកោសល្យត្រឹមត្រូវ

- សាលាទទួលបានការវាយតម្លៃពិតៗពីការស្ទង់មតិ និង ការចុះអធិការកិច្ច ក្នុងការបំពេញនូវចំណុចខ្វះខាត និង បន្តសកម្មភាពវិជ្ជាមានរបស់ខ្លួន
- មានសេវាធានារ៉ាប់រងដល់បុគ្គលិក។

### ៤.២.២ ភាពខ្សោយ

- គ្មានជណ្តើរយន្តសម្រាប់សិស្សធ្វើដំណើរឡើងពីព្រោះអគារខ្ពស់ដល់ទៅ១២ ជាន់ជាហេតុធ្វើឱ្យអាណាព្យាបាលមួយចំនួនចង់ផ្លាស់ប្តូរសិស្សទៅសាលាផ្សេងៗ
- ជាសាខាថ្មីទើបចាប់ផ្តើមបើកនៅចុងឆ្នាំ២០១៨ ធ្វើឱ្យបន្ទប់សិក្សាមួយចំនួនមិនទាន់រៀបចំបានសព្វគ្រប់ ដោយមានការតុបតែងច្រើនដង ធ្វើឱ្យខាតបង់ពេលវេលា និង ថវិការ ព្រមទាំងប៉ះពាល់ដល់ដំណើរការសិក្សា និង កិច្ចការរបស់សាលារៀន។

### ៤.២.៣ ឱកាស

- មានការជម្រុញលើកទឹកចិត្តពីរាជរដ្ឋាភិបាល ព្រោះវិស័យអប់រំជាវិស័យអាទិភាពមួយក្នុងប្រទេសកម្ពុជា។
- សេដ្ឋកិច្ចប្រទេសកម្ពុជាមានការងើបឡើងវិញ ឪពុកម្តាយ និងអាណាព្យាបាលសម្លឹងរកសាលាដែលមានគុណភាពសម្រាប់ផ្តល់ការអប់រំដល់កូន។

### ៤.២.៤ ការគំរាមកំហែង

- ការកើនឡើងនៃសាលាចំណេះទូទៅឯកជន បានធ្វើឱ្យដៃគូប្រកួតប្រជែងលើវិស័យអប់រំកាន់តែច្រើនឡើង
- វិបត្តិសេដ្ឋកិច្ចនានាដែលកើតមានធ្វើឱ្យចំណូលរបស់ប្រជាជនធ្លាក់ចុះ។

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទ « សកម្មភាពអប់រំកម្រិតបឋមសិក្សាជាភាសាជាតិនៃសាលារៀន សុវណ្ណភូមិ សាខាបឹងត្របែក» មក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងថ្មីៗពីការផ្តល់សេវាអប់រំ និង ការងាររដ្ឋបាលខ្លះៗនៅសាលារៀននេះ។ លើសពីនេះទៅទៀត ក្រុមយើងខ្ញុំក៏ទទួលបាននូវបទពិសោធន៍ជាច្រើននៃការស្វែងរកឯកសារ ការវិភាគSWOT ការរៀបចំរបាយការណ៍កម្មសិក្សា ការប្រាស្រ័យទាក់ទងទាំងក្នុង និង ក្រៅស្ថាប័ន និង ការស្នើសុំឯកសារជាដើម។ មិនតែប៉ុណ្ណោះ ក្រុមយើងខ្ញុំបានបញ្ចប់កម្មសិក្សា និង ការសិក្សាស្រាវជ្រាវនេះដោយទាញបាននូវសេចក្តីសន្និដ្ឋានដូចខាងក្រោម៖

- សាលារៀន សុវណ្ណភូមិ បឹងត្របែក មានកេរ្តិ៍ឈ្មោះក្នុងវិស័យអប់រំ ហើយជាសាលាចំណេះទូទៅឯកជនដែលទទួលបានការគាំទ្រយ៉ាងខ្លាំងពីអាណាព្យាបាល និង សិស្សានុសិស្ស។ ជាមួយគ្នានេះផងដែរ គណៈគ្រប់គ្រងសាលាគ្រប់ផ្នែកទាំងអស់មានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការដឹកនាំទៅលើវិស័យអប់រំចំណេះទូទៅខ្មែរ ហើយសាលាក៏ត្រូវបានទទួលស្គាល់ដោយក្រសួង អប់រំ យុវជន និងកីឡា។ ជាងនេះទៅទៀត សាលាទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងវិស័យអប់រំ ព្រមទាំងទទួលបានសមិទ្ធផលជាច្រើនទៀតផង។ មិនតែប៉ុណ្ណោះ សាលាផ្តល់នូវបរិស្ថានសិក្សាល្អ និងប្រព័ន្ធសុវត្ថិភាពខ្ពស់ដល់សិស្សានុសិស្សដែលជាភាពកក់ក្តៅមួយសម្រាប់អាណាព្យាបាល ឬមាតាបិតាសិស្ស។

- ទន្ទឹមនឹងនេះផងដែរ សាលារៀន សុវណ្ណភូមិ បឹងត្របែក ក៏បានជួបប្រទះបញ្ហាឧបសគ្គខ្លះៗ ផងដែរក្នុងសកម្មភាពអប់រំ ដូចជាបញ្ហាជាច្រើនរបស់សិស្សគឺជាក្តីកង្វល់ដែលសាលាត្រូវប្រឈមមុខជារៀងរាល់ថ្ងៃ និងការតុបតែងអគារច្រើនលើកច្រើនសារជាហេតុធ្វើឱ្យរំខានដល់សកម្មភាពសិក្សារបស់សិស្ស។

សរុបសេចក្តីមក សកម្មភាពអប់រំដែលពោរពេញដោយបទពិសោធន៍ និងការយកចិត្តទុកដាក់របស់សាលារៀន សុវណ្ណភូមិ បឹងត្របែក បានទទួលលទ្ធផលជាការគាំទ្រយ៉ាងខ្លាំងពីសំណាក់អាណាព្យាបាល និង ក្រសួងអប់រំ យុវជន និងកីឡា។ ម្យ៉ាងវិញទៀត សាលាក៏បានព្យាយាមរិះរកដំណោះស្រាយ និង មធ្យោបាយដ៏ល្អដើម្បីឆ្លើយតបទៅនឹងបញ្ហាឧបសគ្គដែលកើតមានផងដែរ។

## ការផ្ដល់អនុសាសន៍

ក្នុងការចូលរួមបញ្ចេញមតិយោបល់ ដើម្បីស្ដាបនាទៅលើសកម្មភាពអប់រំនៃសាលារៀនសុវណ្ណភូមិ បឹងត្របែក ក្រុមយើងខ្ញុំសូមលើកជាអនុសាសន៍ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមឱ្យមានការដាក់ SLIDE គ្រប់បន្ទប់នៃផ្នែកបឋមសិក្សា ព្រោះថ្នាក់កុមារគឺត្រូវមានការបង្រៀនដោយភ្ជាប់ជាមួយនឹងរូបភាពផ្ទាល់ដើម្បីឱ្យពួកគេបានប្រើប្រាស់នូវបំណិន សង្កេត គិត ឆ្លើយ សួរ ឱ្យបានច្រើន ព្រមទាំងមានការចាក់នូវវីដេអូខ្លីៗដើម្បីកុំឱ្យកុមារមានការធុញទ្រាន់។
- ត្រូវមានទូរទស្សន៍ដាក់នូវបន្ទប់បណ្ណាល័យ ដើម្បីជាជំនួយដល់កុមារតូចក្នុងការអានសៀវភៅបែបរូបភាព